# ខុទ្ទកនិកាយគាថាធម្មបទ

## វគ្គទី ១៣

## ឈ្មោះលោកវគ្គ

ប្រែ និងរៀបរៀងដោយ ភិក្ខុ សុវណ្ណថេរោ **លឹម ធន់**

**ខេត្តបាត់ដំបង ព.ស ២៥៥០**

# ខុទ្ទកនិកាយគាថាធម្មបទ

## វគ្គទី ១៣

## ឈ្មោះលោកវគ្គ

ប្រែ និងរៀបរៀងដោយ ភិក្ខុ សុវណ្ណថេរោ **លឹម ធន់**

**ខេត្តបាត់ដំបង ព.ស ២៥៥០**

# ខុទ្ទកនិកាយ គាថាធម្មបទ

## លោកវគ្គ វគ្គទី ១៣

១ ហីនំ ធម្មំ ន សេវេយ្យ  បមាទេន ន សំវសេ
មិច្ឆាទិដ្ឋឹ ន សេវេយ្យ  ន សិយា លោកវឌ្ឍនោ ។

បុគ្គលមិនគួរសេពធម៌ថោកទាប មិនគួរនៅដោយសេចក្ដីប្រមាទ មិនគួរសេពមិច្ឆាទិដ្ឋិ មិនគួរជាមនុស្សចង្អៀតលោក ។

២ ឧត្តិដ្ឋេ នប្បមជ្ជេយ្យ  ធម្មំ សុចរិតំ ចរេ
ធម្មចារី សុខំ សេតិ  អស្មឹ លោកេ បរម្ហិ ច
ធម្មំ ចរេ សុចរិតំ  ន តំ ទុច្ចរិតំ ចរេ
ធម្មចារី សុខំ សេតិ  អស្មឹ លោកេ បរម្ហិ ច ។

បុគ្គលមិនគួរប្រមាទក្នុងដុំបាយ ដែលខ្លួនគប្បីក្រោកឡើងទទួល គប្បីប្រព្រឹត្តធមឲ្យសុចរិត បុគ្គលអ្នកប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខក្នុងលោកនេះផង ក្នុងលោកខាងមុខផង, បុគ្គលគួរប្រព្រឹត្តធម៌ឲ្យសុចរិត មិនគួរប្រព្រឹត្តធម៌នោះឲ្យទុច្ចរិតឡើយ បុគ្គលប្រព្រឹត្តធម៌ជាប្រក្រតី រមែង

ដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

៣ យថា បុព្វុឡកំ បស្សេ យថា បស្សេ មរីចិកំ
ឯវំ លោកំ អវេក្ខន្តំ មច្ចុរាជា ន បស្សតិ

បុគ្គលឃើញពពុះទឹកយ៉ាងណា ឃើញព្រេញថ្ងៃយ៉ាងណា ស្តេចមច្ចុ មិនឃើញអ្នកពិចារណាខន្ធលោកជាដើម យ៉ាងនោះទេ ។

៤ ឯថ បស្សថិមំ លោកំ ចិត្តំ រាជរថូបមំ
យត្ថ ពាលា វិសីទន្តិ នត្ថិ សង្គោ វិជានតំ ។

អ្នកទាំងឡាយ ចូរមកមើលលោកនេះ ដ៏ត្រកាលដូចរាជរថ ជនពាលទាំងឡាយ រមែងលិចលង់ក្នុងលោកណា សេចក្ដីជាប់ជំពាក់ក្នុងលោកនោះ រមែងមិនមាន ដល់ជនជាបណ្ឌិតទាំងឡាយ ដែលដឹងច្បាស់ទេ ។

៥ យោ ច បុព្វេ បមជ្ជិត្វា បច្ឆា សោ នប្បមជ្ជតិ
សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ។

បុគ្គលណាមួយ កាលពីមុនប្រមាទហើយ លុះកាលជាខាងក្រោយ គេមិនប្រមាទវិញ បុគ្គលនោះឈ្មោះថា ញុាំងខន្ធាទិលោកនេះ ឲ្យភ្លឺច្បាស់ ដូចព្រះច័ន្ទរះផុតចាកពពក ។

៦ យស្ស កម្មំ កតំ បាបំ    កុសលេន បិថីយតិ
សោមំ លោកំ បភាសេតិ    អព្ភា មុត្តោវ ចន្ទិមា ។

បុគ្គលណា ធ្វើអំពើបាបហើយ បិទខ្ទប់អំពើបាប នោះដោយកុសល គឺអរហត្តមគ្គបាន បុគ្គលនោះ ឈ្មោះថា ញ៉ាំងខន្ធាទិលោកនេះ ឲ្យភ្លឺច្បាស់ ដូចដួង ច័ន្ទរះផុតចាកពពក ។

៧ អន្ធភូតោ អយំ លោកោ    តនុកេត្ថ វិបស្សតិ
សកុណោ ជាលមុត្តោវ    អប្បោ សគ្គាយ គច្ឆតិ ។

មហាជននេះ ជាមនុស្សងងឹត បណ្តាជនទាំងនេះ ជនតិចគ្នា ដែលឃើញច្បាស់ ជនតិចគ្នា ដែលទៅ កាន់ឋានសួគ៌ ដូចសត្វស្លាប ( ដែលជាប់សំណាញ់ របស់ព្រានហើយ ) តិចណាស់ ដែលរួចចាកអំពី សំណាញ់ដូច្នោះ ។

៨ ហំសា អាទិច្ចបថេ យន្តិ    អកាសេ យន្តិ ឥទ្ធិយា
នីយន្តិ ធីរា លោកម្ហា    ជេត្វា មារំ សវាហនំ ។

ពួកហង្សតែងហើរទៅ ក្នុងគន្លងផ្លូវព្រះអាទិត្យ អ្នកមានឫទ្ធិតែងហោះទៅក្នុងអាកាសដោយឫទ្ធិ អ្នក ប្រាជ្ញផ្ចាញ់កិលេសមារ ព្រមទាំងពាហនៈ គឺតណ្ហា បានហើយ រមែងរលាស់ខ្លួនចេញចាកលោកបាន ។

៩ ឯកំ ធម្មំ អតីតស្ស     មុសាវាទិស្ស ជន្តុនោ
វិតិណ្ណបរលោកស្ស     នត្ថិ បាបំ អការិយំ ។

បុគ្គលប្រព្រឹត្តកន្លង ( ពាក្យសច្ចៈ ) ដែលជាធម៌ឯក និយាយតែពាក្យកុហក មានបរលោកលះចោលហើយ ឈ្មោះថាមិនធ្វើអំពើបាប មិនមែនឡើយ ។

១០ ន វេ កទរិយា ទេវលោកំ វជន្តិ
ពាលា ហវេ នប្បសំសន្តិ ទានំ
ធីរោ ច ទានំ អនុមោទមានោ
តេនេវ សោ ហោតិ សុខី បរត្ថ ។

បុគ្គលកំណាញ់ស្វិតស្វាញ មិនបានទៅកាន់ទេវលោកទេ ជនពាលទាំងឡាយ មិនសរសើរទានឡើយ ចំណែកអ្នកប្រាជ្ញ តែងអនុមោទាន ព្រោះហេតុនោះ លោកតែងបានសេចក្តីសុខក្នុងលោកខាងមុខ ។

១១ បឋព្យា ឯករជ្ជេន     សគ្គស្ស គមនេន វា
សព្វលោកាធិបច្ចេន     សោតាបត្តិផលំ វរំ ។

សោតាបត្តិផល ជាគុណជាតដ៏ប្រសើរជាងភាពនៃឯករាជ្យលើផែនដីផង ជាដំណើរទៅកាន់ឋានសួគ៌ផង ជាងភាពជាធំក្នុងលោកទាំងមូលផង ។

# ១៣ លោកវគ្គវណ្ណនា

## ១ រឿងភិក្ខុកំលោះ

### *សេចក្តីខាងដើម*

*ព្រះសាស្តា កាលគង់នៅក្នុងជេតពន ទ្រង់ប្រារព្ធភិក្ខុកំលោះមួយរូប ត្រាស់ព្រះធម្មទេសនានេះថា **"ហីនំ ធម្មំ"** ជាដើម ។*

### *ភិក្ខុឈ្លោះជាមួយចៅស្រីនាងវិសាខា*

*បានឮថា ព្រះថេរៈមួយអង្គ បានទៅកាន់ផ្ទះនាងវិសាខា ជាមួយនឹងភិក្ខុកំលោះតាំងអំពីព្រលឹម ។ ធុរយាគូ ដែលគេតាក់តែងទុកដើម្បីភិក្ខុ ៥០០ រូបមានប្រចាំជានិច្ច ក្នុងផ្ទះនាងវិសាខា ។ ព្រះថេរៈឆាន់បបរហើយ ឲ្យភិក្ខុកំលោះអង្គុយលើផ្ទះរបស់នាងវិសាខានោះ ។ ឯខ្លួនឯង បានទៅកាន់ផ្ទះដទៃ ។ ក៏សម័យនោះ ធីតារបស់បុត្រនាងវិសាខា តាំងនៅក្នុងតំណែងរបស់យាយ ធ្វើការខ្វល់ខ្វាយដល់ភិក្ខុទាំងឡាយ ។ នាងត្រង*

ទឹកដើម្បីភិក្ខុកំលោះនោះ ឃើញស្រមោលមុខរបស់ខ្លួនក្នុងផ្តិល ក៏សើច ។ ឯភិក្ខុកំលោះសំឡឹងមើលនាង ក៏សើចដែរ ។ នាង ឃើញភិក្ខុកំលោះនោះសើច ក៏ពោលថា មនុស្សដាច់ក្បាល សើច ។ លំដាប់នោះ ភិក្ខុកំលោះជេរនាងថា នាងក៏ដាច់ក្បាល, មាតាបិតានាងក៏ដាច់ក្បាលដែរ ។ នាងស្រែកយំទៅកាន់សំណាក់ របស់យាយក្នុងរោងបាយ កាលនាងវិសាខាពោលថា នេះអ្វី នាង ? ក៏បានប្រាប់សេចក្តីនោះ ។ នាងវិសាខានោះមកកាន់ សំណាក់ភិក្ខុកំលោះហើយ និយាយថា លោកម្ចាស់កុំក្រោធ ឡើយ, ពាក្យនោះជាពាក្យមិនធ្ងន់ធ្ងរសំរាប់លោកម្ចាស់ ដែល មានសក់ និងក្រចកកាត់ហើយ មានសំពត់ស្លៀក និងសំពត់ ដណ្តប់កាត់ហើយ អ្នកកាន់អំបែងដាច់ត្រង់កណ្តាល ត្រាច់ទៅ ដើម្បីភិក្ខាទេ ។ ភិក្ខុកំលោះនិយាយថា អើ ឧបាសិកា នាង ជ្រាបភាពដែលអាត្មាជាអ្នកមានសក់កាត់ហើយជាដើម, តែការ ដែលចៅរបស់នាងនេះជេរអាត្មាថា អ្នកមានក្បាលដាច់ដូច្នេះ គួរឬ ? នាងវិសាខាមិនអាចដើម្បីឲ្យភិក្ខុកំលោះ និងចៅស្រី ព្រមព្រៀងគ្នាឡើយ ។ ខណៈនោះ ព្រះថេរៈមកហើយ សួរ ថា នេះដូចម្តេច ឧបាសិកា ? ស្តាប់សេចក្តីនោះហើយ ពោល

ប្រដៅភិក្ខុកំលោះថា អ្នកមានអាយុ អ្នកចូរចេញទៅ, ស្ត្រីនេះមិនបានជេរ អ្នកដែលមានសក់ ក្រួចក និងសំពត់កាត់ហើយ អ្នកកាន់អំបែង ដាច់ត្រង់កណ្តាលត្រាច់ទៅដើម្បីភិក្ខាទេ, អ្នកចូរស្ងៀមទៅ ។

ភិក្ខុកំលោះ.អើ លោកម្ចាស់ លោកមិនគាំពារឧបជ្ឈាយិកា របស់ខ្លួន នឹងគាំពារខ្ញុំធ្វើអ្វី ? កាលដែលនាងជេរខ្ញុំករុណាថា អ្នកមានក្បាលដាច់ នឹងគួរឬ ?

ខណៈនោះ ព្រះសាស្តាស្តេចមកត្រាស់សួរថា នេះដូចម្តេច ? នាងវិសាខា ក៏បានក្រាបទូលហេតុនោះតាំងអំពីដើម ។

## ព្រះសាស្តាប្រទានឱវាទដល់ភិក្ខុកំលោះ

ព្រះសាស្តា ទ្រង់ឃើញឧបនិស្ស័យ នៃសោតាបត្តិផល របស់ភិក្ខុកំលោះហើយ ទ្រង់តម្រិះថា តថាគតបណ្តោយតាមភិក្ខុនេះគួរ ហើយក៏ត្រាស់នឹងនាងវិសាខាថា វិសាខា ចុះទារិការបស់នាង ជេរពួកសាវករបស់តថាគត ថាជាអ្នកមានក្បាលដាច់ គួរឬ ? ភិក្ខុកំលោះក៏ក្រោកឡើង ផ្គងអញ្ជលីក្នុងខណៈនោះឯង ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គទ្រង់ជ្រាបបញ្ហានោះដោយល្អ, ឧបជ្ឈាយ៍របស់ខ្ញុំព្រះអង្គ និងមហា

ឧបាសិកាមិនជ្រាបដោយល្អទេ ។ ព្រះសាស្តា ទ្រង់ជ្រាបភាព ដែលព្រះអង្គ ជាអ្នកអនុគ្រោះដល់ភិក្ខុកំលោះហើយ ត្រាស់ថា ភាវៈ គឺការសើចប្រារព្ធកាមគុណ ដែលជាធម៌ថោកទាប,ទាំង ការសេពធម៌ដែលថោកទាប និងការនៅរួមនឹងសេចក្តីប្រមាទ មិនគួរឡើយ ហើយក៏ត្រាស់ព្រះគាថានេះថា ៖

**១ ហីនំ ធម្មំ ន សេវេយ្យ បមាទេន ន សំវសេ**
**មិច្ឆាទិដ្ឋឹ ន សេវេយ្យ ន សិយា លោកវឌ្ឍនោ ។**

បុគ្គលមិនគួរសេពធម៌ថោកទាប មិនគួរនៅដោយ សេចក្តីប្រមាទ មិនគួរសេពមិច្ឆាទិដ្ឋិ មិនគួរជាមនុស្ស បង្អៀតលោក ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ ពីរបទថា **ហីនំ ធម្មំ** បានដល់ ធម៌ គឺកាមគុណ ៥ ។ ពិតណាស់ ធម៌ គឺកាមគុណ ៥ នោះ ដែល ជនទាប ដោយហោចទៅ សូម្បីអូដ្ឋ និងគោជាដើមគប្បីសេព, ធម៌ គឺបញ្ចកាមគុណ រមែងនាំសត្វអ្នកសេព ទៅកើតក្នុងឋាន ទាបទាំងឡាយ មាននរកជាដើម ព្រោះដូច្នោះ ធម៌ គឺបញ្ចកាម

គុណនោះ ទើបឈ្មោះថា ជាធម៌ថោកទាប, បុគ្គលមិនគប្បី សេពធម៌ដ៏ថោកទាបនោះឡើយ ។

បទថា **បមាទេន** មានសេចក្ដីថា មិនគប្បីនៅរួមដោយ សេចក្ដីប្រមាទ ដែលមានការបណ្ដោយសតិជាលក្ខណៈ ។ បទថា **ន សេវេយ្យ** បានដល់ មិនគប្បីប្រកាន់ការឃើញខុស។ បទថា **លោកវឌ្ឍនោ** សេចក្ដីថា ក៏អ្នកណាធ្វើដូច្នេះ, អ្នកនោះ ឈ្មោះថា ជាមនុស្សចង្អៀតលោក, ព្រោះដូច្នោះ មិនគប្បីជា មនុស្សចង្អៀតលោក ព្រោះមិនធ្វើដូច្នោះ ។

ក្នុងកាលចប់ទេសនា ភិក្ខុកំលោះ ក៏បានតាំងនៅក្នុង សោតាបត្តិផល ។ ទេសនាបានជាប្រយោជន៍ដល់ជនទាំង-ឡាយអ្នកប្រជុំគ្នា ដូច្នេះឯង ។៚

( រឿងភិក្ខុកំលោះ ចប់ )

***************

# ២ រឿងព្រះបាទសុទ្ធោទនៈ

## *សេចក្ដីខាងដើម*

*ព្រះសាស្ដា ស្ដេចនៅនានិគ្រោធារាម ទ្រង់ប្រារព្ធព្រះបិតា ត្រាស់ព្រះធម្មទេសនានេះថា* ***“ឧត្តិដ្ឋេ នប្បមជ្ជេយ្យ”*** *ជាដើម ។*

## *ព្រះសាស្ដាស្ដេចទៅក្រុងកបិលពស្ដុគ្រាដំបូង*

*សេចក្ដីពិស្ដារថា សម័យមួយ ព្រះសាស្ដា ស្ដេចទៅក្រុងកបិលពស្ដុបុរី ដោយស្ដេចទៅជាគ្រាដំបូង មានការក្រោកទទួល ដែលព្រះញាតិទាំងឡាយធ្វើហើយ ស្ដេចទៅកាន់និគ្រោ-ធារាម ទ្រង់និម្មិតរតនចង្ក្រមក្នុងអាកាស ចង្ក្រមលើរតនចង្ក្រមនោះ ទ្រង់សំដែងធម៌ដើម្បីទំលាយមានះរបស់ព្រះញាតិទាំង-ឡាយ ។ ព្រះញាតិទាំងឡាយមានចិត្តជ្រះថ្លាហើយ ក៏ថ្វាយបង្គំតាំងអំពីព្រះបាទសុទ្ធោទនៈឡើងទៅ ។ ភ្លៀងបោក្ខរព័ស្សក៏បានធ្លាក់ចុះក្នុងសមាគមនៃព្រះញាតិនោះ ។ កាលមហាជនប្រារព្ធភ្លៀងនោះ សន្ទនាគ្នាហើយ ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវប៉ុណ្ណោះទេ, ក្នុងកាលមុន*

ភ្លៀងបោក្ខរព័ស៍ក៏ធ្លាក់ចុះ ក្នុងសមាគម នៃព្រះញាតិរបស់តថាគតដែរ ហើយក៏ត្រាស់ វេស្សន្តរជាតក ។ បណ្តាព្រះញាតិដែ លស្តាប់ធម្មទេសនាហើយ ក៏ចៀសចេញទៅ សូម្បីតែមួយអង្គ ក៏មិនបាននិមន្តព្រះសាស្តាឡើយ ។ សូម្បីព្រះរាជាក៏មិនបាន ទ្រង់និមន្ត ដោយតម្រិះថា បុត្ររបស់យើងមិនមកកាន់សំណាក់យើង នឹងទៅទីណា ហើយក៏បានស្តេចទៅ ។ ក៏ឯគ្រាស្តេច ទៅហើយ បញ្ជាឲ្យមនុស្សតាក់ តែងបបរជាដើម ឲ្យក្រាលអាសនៈទាំងឡាយ ទុកដើម្បីភិក្ខុ ប្រមាណ ២ ម៉ឺនអង្គ ក្នុងព្រះរាជមន្ទីរ ។

ព្រឹកឡើង ព្រះសាស្តាស្តេចចូលទៅព្រះនគរដើម្បីបិណ្ឌបាត ទ្រង់ពិចារណាថា ព្រះពុទ្ធក្នុងអតីតទាំងឡាយ ស្តេចដល់ព្រះនគរនៃព្រះបិតាហើយ ស្តេចទៅកាន់ត្រកូលនៃព្រះញាតិតែម្តងឬហ្ន៎ ឬថា ស្តេចត្រាច់ទៅបិណ្ឌបាតតាមលំដាប់ ទ្រង់ក៏ឃើញថា ស្តេចត្រាច់ទៅដោយលំដាប់ ដូច្នេះហើយ ទើបនិមន្តទៅដើម្បីបិណ្ឌបាត តាំងអំពីផ្ទះដំបូងមក ។ ព្រះមាតា

របស់ព្រះរាហុល ប្រថាប់គន់លើផ្ទៃប្រាសាទឃើញហើយ ក៏ក្រាបទូលព្រឹត្តិហេតុនោះដល់ព្រះរាជា ព្រះរាជាទ្រង់ចាត់ចែងសំពត់សាដក ប្រញាប់ស្តេចចេញទៅ ថ្វាយបង្គំព្រះសាស្តាហើយ ត្រាស់ថា ព្រះអង្គ ព្រោះហេតុអ្វី បានជាធ្វើឲ្យខ្ញុំព្រះអង្គវិនាស, ព្រះអង្គត្រាច់ទៅដើម្បីភិក្ខា ធ្វើសេចក្តីខ្មាសអៀនឲ្យកើតឡើងដល់ខ្ញុំព្រះអង្គពន់ពេក, ព្រះអង្គធ្វើកម្មមិនគួរហើយ, ការដែលព្រះអង្គត្រាច់ទៅដោយអង្រឹងមាសជាដើម ត្រាច់ទៅដើម្បីភិក្ខាក្នុងនគរនេះនោះឯង ទើបសមគួរ, ព្រះអង្គធ្វើឲ្យខ្ញុំព្រះអង្គខ្មាសអៀនធ្វើអ្វី ។

## ការបិណ្ឌបាតជាវង្សរបស់ព្រះពុទ្ធ

ព្រះសាស្តា. មហាបពិត្រ តថាគតមិនបានឲ្យព្រះអង្គខ្មាសឡើយ តែតថាគតប្រព្រឹត្តតាមវង្សរបស់ខ្លួន ។

ព្រះរាជា. បុត្រ ចុះការត្រាច់ទៅដើម្បីភិក្ខា ហើយចិញ្ចឹមជីវិត ជាវង្សរបស់ខ្ញុំព្រះអង្គឬ ?

ព្រះសាស្តាត្រាស់ថា មហាបពិត្រ នុ៎ះមិនមែនជាវង្សរបស់ព្រះអង្គទេ តែនុ៎ះជាវង្សរបស់តថាគត, ព្រោះព្រះពុទ្ធច្រើន

អគ្គិ ស្តេចត្រាច់ទៅដើម្បីបិណ្ឌបាត ហើយចិញ្ចឹមជីវិតដែរ ដូច្នេះហើយ បានភាសិតព្រះគាថាទាំងនេះថា ៖

**២ ឧត្តិដ្ឋេ នប្បមជ្ជេយ្យ ធម្មំ សុចរិតំ ចរេ**
**ធម្មចារី សុខំ សេតិ អស្មឹ លោកេ បរម្ហិ ច**
**ធម្មំ ចរេ សុចរិតំ ន តំ ទុច្ចរិតំ ចរេ**
**ធម្មចារី សុខំ សេតិ អស្មឹ លោកេ បរម្ហិ ច ។**

បុគ្គលមិនគួរប្រមាទក្នុងដុំបាយ ដែលខ្លួនគប្បីក្រោកឡើងទទួល គប្បីប្រព្រឹត្តធមឲ្យសុចរិត បុគ្គលអ្នកប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង, បុគ្គលគួរប្រព្រឹត្តធម៌ឲ្យសុចរិត មិនគួរប្រព្រឹត្តធម៌នោះឲ្យទុច្ចរិតឡើយ បុគ្គលប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **ឧត្តិដ្ឋេ** សេចក្តីថា ក្នុងដុំបាយ ដែលខ្លួនត្រូវក្រោកឈរឡើងទទួល ត្រង់ទ្វារផ្ទះរបស់ពួកជនដទៃ ។ បទថា **នប្បមជ្ជេយ្យ** សេចក្តីថា ក៏ភិក្ខុធ្វើឲ្យ

ធម្មទាំនៀមរបស់អ្នកត្រាច់បិណ្ឌបាតជាវត្តសាបសូន្យ ហើយស្វែងរកភោជនដ៏ប្រណីត ឈ្មោះថា ប្រមាទក្នុងដុំបាយដែលខ្លួនគប្បីក្រោកឡើងទទួល, តែថា កាលត្រាច់ទៅតាមលំដាប់ប្រកលួកដើម្បីបិណ្ឌបាត ឈ្មោះថា មិនប្រមាទ ។ ធ្វើយ៉ាងនេះ ទើបឈ្មោះថា មិនគប្បីប្រមាទក្នុងដុំបាយដែលខ្លួនគប្បីក្រោកឈរឡើងទទួល ។

បទថា **ធម្មំ** សេចក្តីថា កាលលះអនេសនៈ ( ការស្វែងរកមិនគួរ ) ចេញហើយ ត្រាច់ទៅតាមលំដាប់ប្រកលួក ឈ្មោះថា គប្បីប្រព្រឹត្តធម៌ គឺការត្រាច់ទៅដើម្បីភិក្ខានោះនុ៎ះឯង ឲ្យជាសុចរិត ។ ពាក្យថា ***សុខំ សេតិ*** នុ៎ះ ត្រឹមតែជាទេសនា ។ អធិប្បាយថា កាលប្រព្រឹត្តធម៌ គឺការត្រាច់ទៅដើម្បីភិក្ខា ឈ្មោះថា ប្រព្រឹត្តធម៌ជាប្រក្រតី រមែងនៅជាសុខដោយឥរិយាបថទាំង ៤ ក្នុងលោកនេះ និងលោកខាងមុខ ។

ពីរបទថា **ន តំ ទុច្ចរិតំ** សេចក្តីថា កាលត្រាច់ទៅក្នុងអគោចរ ផ្សេងដោយអគោចរ មានស្ត្រីពេស្យាជាដើម ឈ្មោះថា រមែងប្រព្រឹត្តធម៌ គឺការត្រាច់ទៅដើម្បីភិក្ខា ឲ្យជាទុច្ចរិត ។ មិនប្រព្រឹត្តយ៉ាងនោះ គប្បីប្រព្រឹត្តធម៌នោះឲ្យជាសុចរិត, មិន

គប្បីប្រព្រឹត្តធម៌នោះឲ្យជាទុច្ចរិតឡើយ ។ ពាក្យដ៏សេសមាន សេចក្តីដូចពោលហើយ ។

ក្នុងកាលចប់ទេសនា ព្រះរាជាតាំងនៅក្នុងសោតាបត្តិ-ផល, ទេសនាបានមានប្រយោជន៍ដល់ជនទាំងឡាយ ដែលប្រជុំគ្នា ដូច្នេះឯង ៕

( រឿងព្រះបាទសុទ្ធោទនៈ ចប់ )

********************

## ៣ រឿងភិក្ខុអ្នកចំរើនវិបស្សនា

### សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអ្នកចំរើនវិបស្សនាប្រមាណ ៥០០ រូប ត្រាស់ព្រះធម្មទេសនានេះថា "**យថា បុព្វុឡកំ បស្សេ**" ជាដើម ។

### ភិក្ខុកាន់យកព្រេញថ្ងៃជាអារម្មណ៍

បានឮថា ភិក្ខុទាំងនោះ រៀនកម្មដ្ឋានក្នុងសំណាក់ព្រះ-សាស្ដាហើយ ចូលទៅព្រៃខំប្រឹងប្រែង ក៏នៅមិនបានសំរេចគុណវិសេស ទើបគិតថា ពួកយើងនឹងរៀនកម្មដ្ឋានឲ្យវិសេសឡើងថែមទៀត កំពុងមកកាន់របស់ព្រះសាស្ដា ឃើញថ្ងៃប-ណ្ដើរកូនពាក់កណ្ដាលផ្លូវ ចំរើនកម្មដ្ឋានដែលមានថ្ងៃបណ្ដើរកូនជាអារម្មណ៍នោះឯងបណ្ដើរ ដើរមកបណ្ដើរ ។ ភ្លៀងក៏ធ្លាក់ក្នុងខណៈដែល ភិក្ខុទាំងនោះចូលទៅកាន់វិហារនោះឯង ។ ភិក្ខុទាំងនោះឈរត្រង់ខាងមុខនោះៗ ឃើញពពុះទឹកទាំងឡាយប៉ោងឡើងហើយ បែកទៅវិញ ដោយសន្ទុះនៃខ្សែទឹក ក៏កាន់យកជាអារម្មណ៍ថា អត្តភាពនេះក៏ដូចជាពពុះទឹក ព្រោះកើត

ឡើងហើយបែកធ្លាយទៅវិញ ។ ព្រះសាស្ដាប្រថាប់គង់ក្នុងព្រះគន្ធកុដិនោះឯង ទ្រង់ប្រមើលមើលភិក្ខុនោះហើយ ទ្រង់ផ្សាយព្រះឱភាស ដូចជាត្រាស់នឹងភិក្ខុទាំងនោះ ហើយត្រាស់ព្រះគាថានេះថា ៖

**៣ យថា បុព្វុឡកំ បស្សេ  យថា បស្សេ មរីចិកំ**
**ឯវំ លោកំ អវេក្ខន្តំ  មច្ចុរាជា ន បស្សតិ**

បុគ្គលឃើញពពុះទឹកយ៉ាងណា ឃើញព្រេញថ្ងៃយ៉ាងណា ស្ដេចមច្ចុ មិនឃើញអ្នកពិចារណាខន្ធលោកជាដើម យ៉ាងនោះទេ ។

# អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **មរីចិកំ** គឺព្រេញថ្ងៃ ពិតណាស់ ព្រេញថ្ងៃ សូម្បីប្រាកដឡើងអំពីទីឆ្ងាយ ដោយអំណាចមានសណ្ឋាន ដូចសណ្ឋានផ្ទះជាដើម តែជារូបដែលកាន់យកមិនបាន ជារបស់សូន្យទទេ ( ប្រាកដច្បាស់ ) ដល់ជនទាំងឡាយ អ្នកចូលទៅជិត, ព្រោះហេតុដូច្នោះ ទើបមានអធិប្បាយថា ស្ដេចមច្ចុ រមែងមិនឃើញបុគ្គលអ្នកពិចារណាឃើញនូវលោក មានខន្ធជាដើម ដូចបុគ្គលឃើញពពុះទឹក ព្រោះអត្ថថា

កើតឡើងហើយ បែកធ្លាយទៅ និងដូចបុគ្គល ឃើញព្រេញថ្ងៃ ព្រោះជាធម្មជាតិស្ងួនទ្យេទជាដើម ដូច្នោះ ។

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះបានសំរេចព្រះអរហត្ត ក្នុងទីខ្ជនអង្គុយនោះឯង ដោយប្រការដូច្នេះ ។ ៚

( រឿងភិក្ខុអ្នកចំរើនវិបស្សនា ចប់ )

***************************

# ៤ រឿងអភយរាជកុមារ

## សេចក្តីខាងដើម

ព្រះសាស្តា ស្តេចនៅនាវេឡុវ័ន ទ្រង់ប្រារព្ធអភយរាជកុមារ ត្រាស់ព្រះធម្មទេសនានេះថា **“ឯថ បស្សថិមំ លោកំ”** ជាដើម ។

## ព្រះកុមារបានទទួលរាជសម្បត្តិ

បានឮថា កាលអភយរាជកុមារនោះ ទ្រង់បង្ក្រាបបច្ចន្តជនបទឲ្យស្ងប់រំងាប់មកហើយ ព្រះបាទពិម្ពិសារជាព្រះបិតាទ្រង់សព្វព្រះហឫទ័យ ព្រះរាជទានស្រីរបាំម្នាក់ ដែលឆ្លាតក្នុងការរាំ និងច្រៀង ហើយបានព្រះរាជទានរាជសម្បត្តិ ៧ ថ្ងៃ ។ អភយរាជកុមារនោះ មិនបានស្តេចចេញខាងក្រៅព្រះរាជមន្ទីរឡើយ សោយសិរីនៃភាពជាព្រះរាជាអស់ ៧ ថ្ងៃ ស្តេចទៅកាន់កំពង់ទឹកក្នុងថ្ងៃទី ៨ ទ្រង់ស្រង់ហើយ ស្តេចចូលទៅកាន់ព្រះឧទ្យាន ប្រថាប់គង់ទតព្រះនេត្រការរាំ និងការច្រៀងរបស់ស្រីនោះ ដូចសន្តតិមហាមាត្យ ។ ក្នុងខណៈនោះឯង ស្ត្រីរបាំនោះ ក៏បានធ្វើមរណកាល ដោយអំណាចខ្យល់ដូចជាសត្រា

ដូចស្ត្រីបាំរបស់សន្តតិមហាមាត្យដែរ ព្រះរាជកុមារមានសេចក្តីសោកកើតឡើងហើយ ព្រោះកាលកិរិយារបស់ស្ត្រីបាំនោះ ទ្រង់តម្រិះថា អ្នកដទៃ វៀរព្រះសាស្តាចេញ នឹងមិនអាចធ្វើសេចក្តីសោកនេះឲ្យរលត់បានឡើយ ហើយក៏ស្តេចចូលទៅគាល់ព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គរំលត់សេចក្តីសោករបស់ខ្ញុំព្រះអង្គផង ។

## ឧបាយរំងាប់សេចក្តីសោក

ព្រះសាស្តា ទ្រង់លួងលោមព្រះកុមារនោះហើយ ត្រាស់ថា ក៏ប្រមាណទឹកភ្នែកទាំងឡាយ ដែលអ្នកទួញយំ ក្នុងកាលនៃស្ត្រីនេះស្លាប់យ៉ាងនេះនេះឯង ឲ្យប្រព្រឹត្តទៅហើយមិនមានក្នុងសង្សារ ដែលមានទីបំផុត ដែលនរណាៗ ដឹងមិនបាន, ទ្រង់ជ្រាបការៈដែលសេចក្តីសោក ជាសភាពស្រោលស្តើងព្រោះទេសនានោះហើយ ទើបមានព្រះពុទ្ធដីកាត្រាស់ថា កុមារអ្នកកុំសោយសោកឡើយ, រឿងនោះជាឋានៈសំរាប់លិចចុះរបស់ជនពាលទាំងឡាយ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា ៖

៤ ៦៨ បស្សថិមំ លោកំ ចិត្តំ រាជរថូបមំ

*យត្ថ ពាលា វិសីទន្តិ          នត្ថិ សង្គោ វិជានតំ ។*

*អ្នកទាំងឡាយ ចូរមកមើលលោកនេះ ដ៏ត្រកាល ដូចរាជរថ ជនពាលទាំងឡាយ រមែងលិចលង់ក្នុង លោកណា សេចក្ដីជាប់ជំពាក់ក្នុងលោកនោះ រមែង មិនមាន ដល់ជនជាបណ្ឌិតទាំងឡាយ ដែលដឹង ច្បាស់ទេ ។*

## អធិប្បាយគាថា

*បណ្ដាបទទាំងនោះ ពីរបទថា* ***ឯថ បស្សថ*** *ព្រះសាស្ដា ត្រាស់សំដៅយកព្រះរាជកុមារនោះឯង ។ ពីរបទថា* ***ឥមំ លោកំ*** *បានដល់ អត្តភាព ពោលគឺខន្ធលោកជាដើមនេះ ។*

*បទថា* ***ចិត្តំ*** *សេចក្ដីថា ដ៏វិចិត្រដោយគ្រឿងប្រដាប់ មានគ្រឿងប្រដាប់ គឺសំពត់ជាដើម ដូចរាជរថ ដែលវិចិត្រ ដោយគ្រឿងប្រដាប់ មានកែវ ៧ ប្រការជាដើម ។ ពីរបទថា* ***យត្ថ ពាលា*** *សេចក្ដីថា ពួកជនពាលប៉ុណ្ណោះលិចលង់ក្នុង អត្តភាពណា ។ បទថា* ***វិជានតំ*** *សេចក្ដីថា តែសំរាប់ពួកអ្នក ដឹង គឺបណ្ឌិតទាំងឡាយ ដែលមិនមានសេចក្ដីជាប់ជំពាក់ ក្នុង*

កិលេសដែលជាគ្រឿងជាប់ជំពាក់ មានរាគៈជាដើម សូម្បីតែមួយក្នុងអត្តភាពនោះ ។

ក្នុងកាលចប់ទេសនា ព្រះរាជកុមារតាំងនៅក្នុងសោតាបត្តិផល, ព្រះធម្មទេសនាបានមានប្រយោជន៍ដល់ជនអ្នកប្រជុំគ្នា ដូច្នេះឯង ។៚

( រឿងអកយរាជកុមារ ចប់ )

*******************

# ៥ រឿងព្រះសម្ពូជនត្ថេរ

## សេចក្តីខាងដើម

ព្រះសាស្តា ស្តេចនៅនាវេឡុវ័ន ទ្រង់ប្រារព្ធព្រះសម្ពូជនត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា “**យោ ច បុព្វេ បមជ្ជិត្វា**” ជាដើម ។

## អ្នកមិនប្រមាទរមែងញ៉ាំងលោកឲ្យភ្លឺ

បានឮថា ព្រះថេរៈនោះ មិនប្រមាណវេលាថា ព្រឹក ឬ រសៀលទេ តែងត្រាច់បោសរឿយៗ ។ ថ្ងៃមួយ ព្រះថេរៈនោះ កាន់អំបោសទៅកាន់សំណាក់របស់ព្រះរេវតត្ថេរ ដែលអង្គុយក្នុងទីសំរាកពេលថ្ងៃ បានពោលថា ព្រះថេរៈនេះ មហាកំជិល, បរិភោគរបស់ដែលជនឲ្យដោយសទ្ធាហើយ មកតែអង្គុយ, កាលដែលព្រះថេរៈនុ៎ះកាន់យកអំបោស ហើយបោសត្រង់តែកន្លែងមួយ មិនគួរទេឬ ។ ព្រះថេរៈគិតថា យើងនឹងឲ្យឱវាទ ដល់លោក ហើយក៏ពោលថា មកនេ៎ះ អាវុសោ ។

ព្រះសម្ពូជនត្ថេរ. អ្វី លោកម្ចាស់ ?

ព្រះរេវតត្ថេរ. លោកចូរទៅ, ស្រង់ទឹកហើយ សឹមមក ។

ព្រះសម្មជ្ជនត្ថេរនោះ ក៏បានធ្វើដូច្នោះ ។

លំដាប់នោះ ព្រះថេរៈឲ្យលោកអង្គុយក្នុងទីដ៏សមគួរមួយហើយ ពោលប្រដៅថា អាវុសោ ធម្មតាភិក្ខុដើរតែបោសគ្រប់វេលា មិនគួរទេ, គឺការដែលភិក្ខុបោសអំពីព្រលឹម ហើយត្រាច់បិណ្ឌបាត ត្រឡប់អំពីបិណ្ឌបាតហើយ មកអង្គុយក្នុងទីសំរាកពេលថ្ងៃ ឬពេលយប់ ស្វាធ្យាយអាការៈ ៣២ តាំងលក្ខណៈ ការអស់ទៅ និងការសាបសូន្យទៅក្នុងអត្តភាពហើយ ក្រោកឡើងបោសក្នុងវេលារសៀល, ការដែលភិក្ខុមិនបោសគ្រប់កាលជានិច្ច ហើយគប្បីធ្វើឱកាសសំរាប់ខ្លួន ។ ព្រះសម្មជ្ជនត្ថេរនោះតាំងនៅក្នុងឱវាទរបស់ព្រះថេរៈហើយ មិនយូរប៉ុន្មានក៏តាំងនៅក្នុងព្រះអរហត្ត ។ ទីនោះៗ បានជាគំនរសំរាមធំ ។

លំដាប់នោះ ភិក្ខុទាំងឡាយ ពោលនឹងព្រះសម្មជ្ជនត្ថេរនោះថា សម្មជ្ជនត្ថេរ ដ៏មានអាយុ ទីនោះៗ បានជាគំនរសំរាមធំ, ព្រោះហេតុអ្វី ទើបលោកមិនបោសទៀត ?

ព្រះសម្មជ្ជនត្ថេរ. លោកដ៏ចម្រើន ខ្ញុំធ្វើហើយដូច្នោះកាលនៅប្រមាទ, តែឥឡូវនេះ ខ្ញុំជាអ្នកមិនប្រមាទ ។

ភិក្ខុទាំងឡាយនាំគ្នាក្រាបទូលដល់ព្រះសាស្តាថា ភិក្ខុនេះព្យាករអរហត្តផល ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ បុត្ររបស់តថាគត ត្រាច់ចោលក្នុងកាលប្រមាទ ក្នុងពេលមុន, តែឥឡូវនេះ បុត្រតថាគត សំរាកសំរាន្តដោយសុខដែលកើតអំពីមគ្គផល ទើបមិនចោល ហើយត្រាស់ព្រះគាថានេះថា ៖

**៥ យោ ច បុព្វេ បមជ្ជិត្វា បច្ឆា សោ នប្បមជ្ជតិ**
**សោមំ លោកំ បភាសេតិ អព្ភា មុត្តោវ ចន្ទិមា ។**

បុគ្គលណាមួយ កាលពីមុនប្រមាទហើយ លុះកាលជាខាងក្រោយ គេមិនប្រមាទវិញ បុគ្គលនោះឈ្មោះថា ញ៉ាំងឧទ្ធទិលោកនេះ ឲ្យភ្លឺច្បាស់ ដូចព្រះច័ន្ទរះផុតចាកពពក ។

## អធិប្បាយគាថា

បណ្ឌិតគប្បីជ្រាបសេចក្តីនៃព្រះគាថានោះថា ៖

បុគ្គលណា ប្រមាទហើយក្នុងកាលមុន ដោយការធ្វើវត្តនិងបដិវត្តន៍ ឬដោយការស្វាធ្យាយជាដើម ខាងក្រោយសំរាកសំរាន្តដោយសុខ ដែលកើតអំពីមគ្គផល ឈ្មោះថា មិនប្រមាទ,

បុគ្គលនោះ រមែងញ៉ាំងលោក មានខន្ធជាដើមនេះឲ្យភ្លឺ គឺរមែងធ្វើឲ្យភ្លឺច្បាស់តែម្យ៉ាងបានដោយមគ្គញ្ញាណ ដូចដួងច័ន្ទរះផុតហើយចាកពពកជាដើម ញ៉ាំងឱកាសលោកឲ្យភ្លឺដូច្នោះ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនសំរេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

( រឿងព្រះសម្មជ្ជនត្ថេរ ចប់ )

*******************

# ៦ រឿងព្រះអង្គុលិមាលត្ថេរ

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅវត្តជេតពន ទ្រង់ប្រារព្ធព្រះ-អង្គុលិមាលត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា "**យស្ស បាបំ កតំ កម្មំ**" ជាដើម ។

## ដើមរឿងចុងត្រង់ប្រើបាន

សេចក្ដីនៃរឿងបណ្ឌិតគប្បីជ្រាប ដោយអំណាចនៃអង្គុ-លិមាលសូត្រនោះឯង ។ ក៏ព្រះថេរៈ បួសក្នុងសំណាក់ព្រះ-សាស្ដា បានសំរេចព្រះអរហត្ត ។ គ្រានោះឯង ព្រះអង្គុលិមាល ទៅក្នុងទីស្ងប់ស្ងាត់ គេចចេញអំពីពួកក្រុម សោយវិមុត្តិសុខ, បន្លឺឧទាននេះក្នុងវេលានោះថា ៖

អ្នកដែលប្រមាទលើកមុនហើយ ដល់មកខាង
ក្រោយ គេលែងប្រមាទ នឹងញុំាងលោកឲ្យភ្លឺបាន
ដូចព្រះច័ន្ទផុតហើយចាកពពក ចាំងពន្លឺឲ្យភ្លឺច្បាស់
ដូច្នោះឯង ។

លុះបន្ទឹឱទានហើយ ក៏បរិនិព្វានដោយអនុបាទិសេស-និព្វានធាតុ ។ ភិក្ខុទាំងឡាយ សន្ទនាគ្នាក្នុងសាលាធម្មសភាថា អ្នកមានអាយុ ព្រះថេរៈកើតក្នុងទីណាហ្ន៎ ? ព្រះសាស្ដា ស្ដេចមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកអ្នក អង្គុយសន្ទនាគ្នាដោយពាក្យពេចន៍អ្វី ? កាលភិក្ខុទាំងនោះក្រាបទូលថា ដោយពាក្យប្រារព្ធដល់ទីកើត របស់ព្រះអង្គុលិ-មាលត្ថេរ ព្រះអង្គ, ក៏ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុត្ររបស់តថាគតបរិនិព្វានហើយ, ភិក្ខុទាំងឡាយទូលសួរថា ព្រះអង្គុ-លិមាលសំលាប់មនុស្សមានប្រមាណប៉ុណ្ណោះ បរិនិព្វានហើយឬ ព្រះអង្គ ? ទើបត្រាស់ថា យ៉ាងនោះហើយ ម្នាលភិក្ខុទាំង-ឡាយ ព្រោះអង្គុលិមាលនោះ មិនបានកល្យាណមិត្តត្រឹមតែម្នាក់ ទើបបានជាធ្វើបាបមានប្រមាណប៉ុណ្ណោះ ក្នុងកាលមុន, តែខាងក្រោយមក បានកល្យាណមិត្តជាបច្ច័យ ទើបជាអ្នកមិនប្រមាទ, ហេតុនោះ បាបកម្មនោះ គឺបុត្ររបស់តថាគតលះបានហើយដោយកុសល ហើយត្រាស់ព្រះគាថានេះថា ៖

៦ យស្ស កម្មំ កតំ បាបំ    កុសលេន បិធីយតិ
សោមំ លោកំ បភាសេតិ    អព្ភា មុត្តោវ ចន្ទិមា ។

បុគ្គលណា ធ្វើអំពើបាបហើយ បិទខ្ទប់អំពើបាប នោះដោយកុសល បុគ្គលនោះឈ្មោះថា ញុំាងឱខន្ធាទិ-លោកនេះ ឲ្យភ្លឺច្បាស់ ដូចដួងច័ន្ទរះផុតចាកពពក ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **កុសលេន** ព្រះសាស្តាត្រាស់សំដៅយកព្រះអរហត្តមគ្គ ។ ពាក្យដ៏សេស មានសេចក្តីរាក់ទាំងអស់ ។

ក្នុងវេលាចប់ទេសនា ជនជាច្រើនបានសំរេចលោកុត្តរផល មានសោតាបត្តិផលជាដើម ។l៚

( រឿងព្រះអង្គុលិមាលត្ថេរ ចប់ )

**************************

# ៧ រឿងធីតាជាងតម្បាញ

## សេចក្តីខាងដើម

ព្រះសាស្តា ស្តេចនៅនាអគ្គាឡវចេតិយ ទ្រង់ប្រារព្ធធីតារបស់ជាងតម្បាញម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **“អន្ធភូតោ អយំ លោកោ”** ជាដើម ។

## ជនចម្រើនមរណស្សតិមិនខ្លាចស្លាប់

សេចក្តីពិស្តារថា ថ្ងៃមួយ ពួកអ្នកក្រុងអាឡវី កាលព្រះសាស្តាស្តេចដល់ក្រុងអាឡវីហើយ ក៏បានទូលនិមន្តថ្វាយទាន ។ ព្រះសាស្តា ទ្រង់ធ្វើអនុមោទនាក្នុងវេលាស្រេចភត្តកិច្ចថា អ្នកទាំងឡាយ ចូរចំរើនមរណស្សតិយ៉ាងនេះថា ជីវិតរបស់យើងមិនទៀងទាត់, សេចក្តីស្លាប់របស់យើងទៀងទាត់, យើងត្រូវស្លាប់ជាប្រាកដ, ជីវិតរបស់យើង មានសេចក្តីស្លាប់ជាទីបំផុត, ជីវិតរបស់យើងមិនទៀង, សេចក្តីស្លាប់ទៀង, ក៏មរណៈដែលជនទាំងឡាយណា មិនបានចំរើនហើយ, ក្នុងកាលទីបំផុតជនទាំងឡាយនោះ តែងតក់ស្លុត ស្រែកសំឡេងគួរឲ្យខ្លាចធ្វើមរណកាល ដូចបុរសឃើញអាសិរពិសហើយខ្លាចដូច្នោះ, រីឯ

មរណៈដែលជនទាំងឡាយណាបានចំរើនហើយ ជនទាំងឡាយនោះ រមែងមិនតក់ស្លុតក្នុងកាលជិតស្លាប់ ដូចបុរសឃើញអាសិរពិសតែអំពីចំងាយ ហើយក៏យកមែកឈើគ្គុះបោលទៅ ឋិតនៅដូច្នោះ, ព្រោះដូច្នោះ អ្នកទាំងឡាយគប្បីចំរើនមរណស្សតិ ។

## ព្រះសាស្តាស្តេចប្រទានឱវាទធីតាជាងតម្បាញ

ពួកជនដ៏សេស ស្តាប់ព្រះធម្មទេសនានោះហើយ បានខ្វល់ខ្វាយតែក្នុងកិច្ចរបស់ខ្លួនប៉ុណ្ណោះ ។ ចំណែកធីតារបស់ជាងតម្បាញអាយុ ១៦ឆ្នាំម្នាក់ គិតថា ឱ! ធម្មតាពាក្យរបស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយអស្ចារ្យ, យើងគួរតែចំរើនមរណស្សតិ ហើយក៏ខំចំរើនតែមរណស្សតិអស់ថ្ងៃ និងយប់ ។ ចំណែកព្រះសាស្តា ស្តេចចេញចាកក្រុងអាឡវីហើយ ក៏បានស្តេចទៅជេតវនារាម ។ នាងកុមារិកានោះ ក៏ចំរើនមរណស្សតិជានិច្ចអស់ ៣ ឆ្នាំ ។ តមកថ្ងៃមួយ ព្រះសាស្តាទ្រង់ប្រមើលមើលលោកក្នុងវេលាទៀបភ្លឺ ទ្រង់ឃើញនាងកុមារិកានោះចូលក្នុងសំណាញ់ គឺព្រះញាណរបស់ព្រះអង្គ ទ្រង់ពិចារណាថា នឹងមានហេតុអ្វីហ្ន៎ ? ទ្រង់ក៏ជ្រាបថា នាងកុមារិកានេះ ចំរើននូវមរណស្សតិអស់ ៣ ឆ្នាំ តាំងអំពីថ្ងៃដែលស្តាប់ធម្មទេសនា

របស់តថាគត, ឥឡូវនេះ តថាគតទៅទីនោះហើយ សួរបញ្ហា ៤ ខ. នឹងនាងកុមារិកានេះ កាលនាងឆ្លើយបញ្ហាចប់ នឹងឲ្យសាធុការ ក្នុងឋានៈទាំង ៤ ហើយភាសិតគាថានេះ, ក្នុងវេលាចប់គាថា នាងកុមារិកានោះ នឹងតាំងនៅក្នុងសោតាបត្តិផល, ព្រោះអាស្រ័យនាងកុមារិកានោះ ទេសនានឹងមានប្រយោជន៍ដល់មហាជន ដូច្នេះហើយ ទ្រង់មានភិក្ខុប្រមាណ ៥០០ រូបជាបរិវារ បានស្តេចចេញចាកជេតវនារាម ទៅកាន់អគ្គាឡវវិហារដោយលំដាប់ ។ ពួកអ្នកក្រុងអាឡវីជ្រាបថា ព្រះសាស្តាស្តេចមកហើយ ក៏បាននាំគ្នាទៅវិហារទូលនិមន្ត ។ ឯនាងកុមារិកានោះ ជ្រាបការស្តេចមករបស់ព្រះសាស្តា មានចិត្តរីករាយថា ឮថា ព្រះមហាគោតម ជាព្រះបិតា ទ្រង់ជាធំ ជាព្រះអាចារ្យទ្រង់មានព្រះភក្ត្រ ដូចព្រះច័ន្ទពេញវង់របស់យើង ស្តេចមកហើយ ទើបគិតថា ព្រះសាស្តាមានពណ៌ដូចមាស យើងធ្លាប់ឃើញអស់ ៣ ឆ្នាំហើយមកដល់ថ្ងៃនេះ, តែឥឡូវនេះ យើងនឹងបានឃើញព្រះសរីរៈ ដែលមានពណ៌ដូចមាស និងបានស្តាប់ធម៌ដែលមានឱជាដ៏ពីរោះចាប់ចិត្ត របស់ព្រះសាស្តានោះ ។

ចំណែកបិតារបស់នាង កាលទៅកាន់រោងតម្បាញ បាន ផ្តាំកូនស្រីទុកថា កូន សំពត់សាដកជារបស់អ្នកដទៃ បិតាកំពុង ត្បាញ, សំពត់នោះ នៅមួយចង្អាមទៀតមិនទាន់សំរេច, បិតា នឹងធ្វើឲ្យស្រេចក្នុងថ្ងៃនេះ, កូនខារហើយ ត្រូវនាំមកឲ្យបិតា យ៉ាងឆាប់រហ័ស ។ នាងកុមារិកានោះគិតថា យើងចង់ស្តាប់ ធម៌របស់ព្រះសាស្តា, តែបិតាប្រើយើងដូច្នេះ, យើងនឹងស្តាប់ ធម៌របស់ព្រះសាស្តា ឬនឹងខារហើយនាំទៅឲ្យបិតា ? គ្រានោះ នាងកុមារិកានោះ មានគំនិតយ៉ាងនេះថា បើយើងមិននាំខ្នារទៅ ឲ្យ បិតាគប្បីវាយយើងខ្លះ ប្រហារយើងខ្លះ,ដូច្នោះ យើងខារឲ្យ គាត់ហើយ សឹមស្តាប់ធម៌ជាខាងក្រោយ ហើយអង្គុយខារលើ តាំង ។ ឯពួកជនអ្នកក្រុងអាឡវី អង្គាសព្រះសាស្តា ហើយ បានទទួលបាត្រ ឋិតនៅដើម្បីចាំទទួលអនុមោទនា ។ ព្រះសា ស្តាបានប្រថាប់ស្ងៀម ដោយទ្រង់តម្រិះថា តថាគត អាស្រ័យ កុលធីតាណាមកហើយអស់ផ្លូវ ៣០ យោជន៍, កុលធីតានោះ មិនមានឱកាសក្នុងថ្ងៃនេះ, កាលកុលធីតាបានឱកាស ទើប តថាគតធ្វើអនុមោទនា ។ ក៏នរណាៗ ក្នុងលោក ព្រមទាំង ទេវលោក មិនអាចនឹងទូលអ្វីៗ នឹងព្រះសាស្តា ដែលទ្រង់

គង់ស្ងៀមយ៉ាងនោះបាន, ចំណែកកុមារិកានោះឯង ខារខ្នារ ហើយដាក់ក្នុង កញ្ច្រែងដើរទៅកាន់សំណាក់របស់បិតា ដល់ចុងបរិស័ទហើយ ក៏បានងាកមើលព្រះសាស្ដាបណ្ដើរ ដើរទៅបណ្ដើរ ។ ឯព្រះសាស្ដា ក៏ទ្រង់អើតព្រះសុរងទតនាងកុមារិកានោះ ។

នាងកុមារិកានោះក៏បានជ្រាបដោយអាការៈដែលព្រះសាស្ដាទតព្រះនេត្រថា

ព្រះសាស្ដាប្រថាប់គង់កណ្ដាលបរិស័ទបែបនោះ ទតព្រះនេត្រមកយើង ទ្រង់រង់ចាំការមករបស់យើង ទ្រង់ចាំការមកកាន់សំណាក់របស់ព្រះអង្គជាប្រាកដ ។ នាងដាក់កញ្ច្រែងខ្នារហើយបានទៅកាន់សំណាក់របស់ព្រះសាស្ដា ។

សួរថា ព្រោះហេតុអ្វី ទើបព្រះសាស្ដាទតព្រះនេត្រមករកនាងកុមារិកានោះ ?

ឆ្លើយថា បានឮថា ព្រះអង្គបានទ្រង់បរិវិតក្កយ៉ាងនេះថា នាងកុមារិកានោះ កាលទៅអំពីទីនេះ ធ្វើមរណកាលរបស់បុថុជ្ជន នឹងជាអ្នកមានគតិមិនទៀងទាត់, តែបើមកកាន់សំណាក់តថាគត ហើយទៅ សំរេចសោតាបត្តិផល នឹងជាអ្នកមានគតិ

ទៀងទាត់ កើតក្នុងតុសិតវិមាន ។ ពុថា ថ្ងៃនោះ នាងកុមារិកា នោះ មិនរួចចាកអំពីសេចក្តីស្លាប់បានទេ ។

នាងកុមារិកានោះចូលទៅគាល់ព្រះសាស្តា ដោយសញ្ញា ដែលព្រះសាស្តាទតព្រះនេត្រនោះឯង ចូលទៅចន្លោះនៃរស្មី មានពណ៌ ៦ ថ្វាយបង្គំហើយ បានឈរនៅក្នុងទីដ៏សមគួរ ។

## ព្រះសាស្តាត្រាស់សួរបញ្ហានឹងធីតាជាងតម្បាញ

ក្នុងខណៈដែលនាងកុមារិកានោះ ថ្វាយបង្គំព្រះសាស្តា ដែលទ្រង់ប្រថាប់គង់ស្ងៀម នាកណ្តាលបរិស័ទបែបនោះហើយ នៅឈរនោះឯង ព្រះសាស្តាត្រាស់នឹងនាងថា កុមារិកានាង មកពីណា ?

កុមារិកា. មិនដឹងទេ ព្រះអង្គ ។

ព្រះសាស្តា. នាងនឹងទៅទីណា ?

កុមារិកា. មិនដឹងទេ ព្រះអង្គ ។

ព្រះសាស្តា. នាងមិនដឹងឬ ?

កុមារិកា. ដឹង ព្រះអង្គ ។

ព្រះសាស្តា. នាងដឹងទេឬ ?

កុមារិកា. មិនដឹងទេ ព្រះអង្គ ។

ព្រះសាស្តា ត្រាស់សួរបញ្ហា ៤ ខ. នឹងកុមារិកានោះ ដោយប្រការដូច្នោះ ។

មហាជនលើកទោសថា អ្នកដ៏ចំរើនទាំងឡាយ លោកទាំងឡាយចូរមើល, ធីតាជាងតម្បាញនេះ និយាយពាក្យដែលខ្លួនប្រាប្ថាហើយៗ នឹងព្រះសម្មាសម្ពុទ្ធ, កាលព្រះសម្មាសម្ពុទ្ធត្រាស់ថា នាងមកពីណា ? ធីតាជាងតម្បាញនេះ គួរនិយាយថា អំពីផ្ទះជាងតម្បាញ, កាលទ្រង់ត្រាស់ថា នាងនឹងទៅទីណា ? ក៏គួរទូលថា ទៅរោងរបស់ជាងតម្បាញ មិនមែនឬ ? ព្រះសាស្តា ទ្រង់ធ្វើមហាជនឲ្យស្ងាត់សំឡេងហើយ ត្រាស់សួរថា កុមារិកា នាងកាលតថាគតពោលថា មកពីណា ? ហេតុអ្វីទើបនាងឆ្លើយថា មិនដឹង ?

កុមារិកា. បពិត្រព្រះអង្គ ព្រះអង្គរមែងទ្រង់ជ្រាបសេចក្តីដែលខ្ញុំព្រះអង្គមកពីផ្ទះជាងតម្បាញ, តែព្រះអង្គត្រាស់សួរថា នាងមកពីណា បំណងត្រាស់សួរថា នាងមកពីណា ទើបកើតក្នុងទីនេះ ? តែខ្ញុំព្រះអង្គមិនដឹងថា យើងមកពីណា ទើបកើតក្នុងទីនេះ ?

លំដាប់នោះ ព្រះសាស្តាប្រទានសាធុការ ជាគ្រាដំបូងដល់នាង កុមារិកានោះថា សាធុ សាធុ កុមារិកា បញ្ហាដែលតថាគតសួរហើយនោះឯង នាងឆ្លើយបានហើយ ត្រាស់សួរតទៅទៀតថា នាង តថាគតសួរថា នាងនឹងទៅទីណា ? ហេតុអ្វីទើបពោលថាមិនដឹង ?

បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គទ្រង់ជ្រាបខ្ញុំព្រះអង្គកាន់កញ្ច្រែងខ្ញារ ដើរទៅកាន់រោងជាងតម្បាញ, តែព្រះអង្គត្រាស់សួរថា ក៏នាងទៅអំពីលោកនេះហើយ នឹងកើតក្នុងទីណា ? ខ្ញុំព្រះអង្គចុតិចាកលោកនេះហើយ រមែងមិនដឹងថា នឹងទៅកើតក្នុងទីណា ?

លំដាប់នោះ ព្រះសាស្តា ប្រទានសាធុការដល់នាងជាលើកទីពីរថា បញ្ហាដែលតថាគតសួរហើយនោះឯង នាងឆ្លើយបាន ហើយត្រាស់សួរតទៅទៀតថា កាលបើដូច្នោះ នាងដែលតថាគតសួរថា នាងមិនដឹងទេឬ ហេតុអ្វីទើបនិយាយថាដឹង ?

កុមារិកា. ខ្ញុំព្រះអង្គជ្រាបតែភាវៈ គឺសេចក្តីស្លាប់របស់ខ្ញុំព្រះអង្គប៉ុណ្ណោះ ព្រះអង្គ, ហេតុនោះ ទើបនិយាយដូច្នោះ ។

លំដាប់នោះ ព្រះសាស្ដា ប្រទានសាធុការដល់នាងជាលើកទី ៣ ថា បញ្ហាដែលតថាគតសួរហើយនោះឯង នាងឆ្លើយបាន ហើយត្រាស់សួរតទៅទៀតថា កាលបើដូច្នោះ, នាងកាលតថាគតសួរថា នាងដឹងទេឬ ? ហេតុអ្វី ទើបនិយាយថាមិនដឹង ?

កុមារិកា. ខ្ញុំព្រះអង្គជ្រាបតែភាវៈ គឺសេចក្ដីស្លាប់របស់ខ្ញុំព្រះអង្គប៉ុណ្ណោះ ព្រះអង្គ, តែមិនដឹងថា នឹងស្លាប់ពេលយប់ពេលថ្ងៃ ឬពេលព្រឹកជាដើមទេ,ព្រោះហេតុនោះ ទើបនិយាយដូច្នោះ ។

## ជនមានបញ្ញាឈ្មោះថាមានចក្ខុ

លំដាប់នោះ ព្រះសាស្ដា ប្រទានសាធុការលើកទី ៤ ដល់នាងថា បញ្ហាដែលតថាគតសួរហើយនោះឯង នាងឆ្លើយត្រូវហើយ រួចត្រាស់ជាស់តឿនបរិស័ទថា ពួកអ្នកមិនដឹងប្រមាណប៉ុណ្ណេះ ដែលនាងកុមារិកានេះពោលហើយទេ, ពោលទោសតែម្យ៉ាងប៉ុណ្ណោះ, ព្រោះចក្ខុ គឺបញ្ញារបស់ពួកជនណាមិនមាន, ពួកជននោះ ដូចជាមនុស្សខ្វាក់, ចក្ខុ គឺបញ្ញារបស់ពួកជនណា

មាន, ជនទាំងនោះនុ៎ះឯង ទើបជាអ្នកមានចក្ខុ ហើយត្រាស់ព្រះគាថានេះថា ៖

**៧ អន្ធភូតោ អយំ លោកោ តនុកេត្ថ វិបស្សតិ**
**សកុណោ ជាលមុត្តោវ អប្បោ សគ្គាយ គច្ឆតិ ។**

មហាជននេះ ជាមនុស្សងងឹត បណ្ដាជនទាំងនេះ ជនតិចគ្នា ដែលឃើញច្បាស់ ជនតិចគ្នា ដែលទៅកាន់ឋានសួគ៌ ដូចសត្វស្លាប ( ដែលជាប់សំណាញ់របស់ព្រានហើយ ) តិចណាស់ ដែលរួចចាកអំពីសំណាញ់ដូច្នោះ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ ពីរបទថា **អយំ លោកោ** សេចក្ដីថា លោកិយមហាជននេះ ដូចជាមនុស្សខ្វាក់ ព្រោះមិនមានចក្ខុគឺបញ្ញា ។ ពីរបទថា **តនុកេត្ថ** សេចក្ដីថា ជនក្នុងលោកនេះតិចនាក់ គឺមិនច្រើន នឹងឃើញច្បាស់ ដោយអំណាចនៃត្រៃលក្ខណ៍ មានមិនទៀងជាដើម ។ បទថា **ជាលមុត្តោវ** បណ្ដាហ្វូងសត្វចាប ដែលនាយព្រានអ្នកឆ្លាត ដាក់អន្ទាក់ចាប់យកសត្វចាបខ្វះប៉ុណ្ណោះ រួចចាកអន្ទាក់បាន, ចាបដ៏សេស រមែង

ចូលទៅខាងក្នុងអន្ទាក់ទាំងអស់ យ៉ាងណា, បណ្តាសត្វដែលជាប់អន្ទាក់ គឺមារគ្របសង្កត់ហើយ សត្វជាច្រើនរមែងទៅកាន់អបាយ, តិចនាក់ គឺមនុស្សខ្លះប៉ុណ្ណោះ ទៅក្នុងសួគ៌ គឺរមែងដល់សុគតិ ឬនិព្វានដូច្នោះ ។

ក្នុងវេលាចប់ទេសនា នាងកុមារិកានោះ តាំងនៅក្នុងសោតាបត្តិផល, ទេសនាបានមានប្រយោជន៍ដល់មហាជន ។

## ធីតាជាងតម្បាញស្លាប់ទៅកើតក្នុងតុសិតភព

ឯនាងកុមារិកានោះ បានកាន់កញ្ច្រែងខ្នារទៅកាន់របស់បិតា ។ ចំណែកបិតានោះ ក៏អង្គុយដេកលក់ ។ កាលនាងមិនកំណត់ហើយ បង្អោនកញ្ច្រែងខ្នារចូលទៅ កញ្ច្រែងខ្នារទង្គិចត្រង់ចុងផ្សំ ធ្វើសំឡេងធ្លាក់ទៅ ។ បិតានោះភ្ញាក់ឡើងហើយកន្ត្រាក់ចុងផ្សំ ដោយនិមិត្តដែលខ្លួនចាប់យកហើយនោះឯង ។ ចុងផ្សំទៅប្រហារនាងកុមារិកានោះត្រង់ទ្រូង,

នាងក៏ស្លាប់នៅត្រង់ ទីនោះឯង ទៅកើតក្នុងតុសិតពិភព ។ លំដាប់នោះ បិតារបស់ នាង ក្រឡេកមើលនាងបានឃើញសរីរៈរបស់នាងទាំងអស់ ប្រឡាក់ដោយលោហិតដួលដេកស្លាប់ហើយ ។ លំដាប់នោះ សេចក្តីសោកដ៏ធំ

កើតឡើងដល់បិតានោះ ។ គាត់ស្រែកយំ ដោយគិតថា អ្នកដទៃទីងមិនអាចរំលត់សេចក្ដីសោករបស់ យើងបានឡើយ ទើបទៅកាន់សំណាក់របស់ព្រះសាស្ដា ក្រាបទូលរឿងនោះហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គទ្រង់ញ៉ាំងសេចក្ដីសោករបស់ខ្ញុំឲ្យរលត់ ។ ព្រះសាស្ដាត្រាស់លួងលោមគាត់ហើយ ត្រាស់ថា អ្នកកុំសោកឡើយ, ព្រោះថា ទឹកភ្នែករបស់អ្នកដែលហូរចេញ ក្នុងកាលដែលធីតារបស់អ្នកស្លាប់ ដោយអាការយ៉ាងនេះ នេះឯង ក្នុងសង្សារដែលគ្មានទីបំផុត ដែលនរណាៗ ដឹងមិនបានហើយ ក្រៃលែងជាងទឹកមហាសមុទ្ទទាំង ៤ ហើយក៏ត្រាស់អនមតគ្គសូត្រ គាត់មានសេចក្ដីសោកស្រាលស្តើង ទូលសូមបព្វជ្ជានឹងព្រះសាស្ដា បានឧបសម្បទាហើយ តមកមិនយូរប៉ុន្មាន ក៏សំរេចព្រះ-អរហត្ត ដូច្នេះឯង ។ល។

( រឿងធីតារបស់ជាងតម្បាញ ចប់ )

*************************

# ៨ រឿងភិក្ខុ ៣០ រូប

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងជេតពន ទ្រង់ប្រារព្ធភិក្ខុ ភិក្ខុ ៣០ រូប ត្រាស់ព្រះធម្មទេសនានេះថា "**ហំសា អាទិច្ច-បថេ យន្តិ**" ជាដើម ។

## អ្នកចម្រើនឥទ្ធិបាទរមែងហោះទៅបាន

សេចក្ដីពិស្ដារថា ក្នុងថ្ងៃមួយ ភិក្ខុអ្នកមានប្រក្រតីនៅក្នុងទិសប្រមាណ ៣០ រូប ចូលទៅគាល់ព្រះសាស្ដា ។ ព្រះអានន្ទត្ថេរ មកក្នុងវេលាដែលធ្វើវត្តដល់ព្រះសាស្ដា ឃើញភិក្ខុទាំងនោះ ហើយ គិតថា កាលព្រះសាស្ដាធ្វើបដិសណ្ឋារៈជាមួយភិក្ខុទាំង នេះហើយ, យើងនឹងធ្វើវត្ត ហើយក៏បានទៅឈរត្រង់ខ្លោង ទ្វារ ។ ចំណែកព្រះសាស្ដា ទ្រង់ធ្វើបដិសណ្ឋារៈជាមួយនឹងភិក្ខុទាំងនោះហើយ ក៏ត្រាស់កថាដែលប្រារព្ធធម៌ ជាគ្រឿងឲ្យរឭកដល់គ្នានឹងគ្នា ដល់ភិក្ខុទាំងនោះ ។ ភិក្ខុទាំងនោះស្ដាប់ធម្មកថានោះ ហើយ

សំរេចព្រះអរហត្តគ្រប់អង្គ បានហោះទៅឰដ៏អាកាស ។ ព្រះអានន្ទត្ថេរ កាលភិក្ខុទាំងនោះនៅយូរ ក៏ចូលទៅគាល់ព្រះសាស្តា ទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុ ៣០ រូប មកក្នុងទីនេះ, ភិក្ខុទាំងនោះទៅណា ?

ព្រះសាស្តា. ម្នាលអានន្ទ បានទៅហើយ ។

អានន្ទ. បពិត្រព្រះអង្គ ទៅតាមផ្លូវណា ?

ព្រះសាស្តា. ម្នាលអានន្ទ ផ្លូវអាកាស ។

អានន្ទ. ចុះភិក្ខុទាំងនោះ ជាព្រះណាស្រេពឬ ព្រះអង្គ ?

ព្រះសាស្តា. ម្នាលអានន្ទ ត្រូវហើយ ភិក្ខុទាំងនោះស្តាប់ធម៌ក្នុងសំណាក់តថាគតបានសំរេចព្រះអរហត្ត ។ ក៏ក្នុងខណៈនោះឯង ហង្សទាំងឡាយហើរទៅ ។ ព្រះសាស្តា ត្រាស់ថា ម្នាលអានន្ទ ឥទ្ធិបាទ ៤ ដែលនរណាចំរើនល្អហើយ, អ្នកនោះរមែងហោះទៅបានដូចហង្សដូច្នោះ ហើយក៏ត្រាស់ព្រះគាថា

**៨ ហំសា អាទិច្ចបថេ យន្តិ អាកាសេ យន្តិ ឥទ្ធិយា**
**នីយន្តិ ធីរា លោកម្ហា ជេត្វា មារំ សវាហនំ ។**

ពួកហង្សតែងហើរទៅ ក្នុងគន្លងផ្លូវព្រះអាទិត្យ
អ្នកមានឫទ្ធិតែងហោះទៅក្នុងអាកាសដោយឫទ្ធិ អ្នក

ប្រាជ្ញផ្ចាញ់កិលេសមារ ព្រមទាំងពាហនៈ គឺតណ្ហា បានហើយ រមែងរលាស់ខ្លួនចេញចាកលោកបាន ។

## អធិប្បាយគាថា

បណ្ឌិតគប្បីជ្រាប សេចក្តីនៃព្រះគាថានោះថា ៖

ហង្សទាំងនេះ រមែងទៅក្នុងផ្លូវនៃដួងអាទិត្យ គឺក្នុងអាកាស ។ ក៏ឥទ្ធិបាទដែលជនពួកណាចំរើនល្អហើយ, ជនពួកនោះឯង រមែងទៅក្នុងអាកាសដោយឫទ្ធិបាន ។ សូម្បីធីរជនទាំងឡាយ គឺបណ្ឌិត ឈ្នះមារ ព្រមទាំងពាហនៈហើយ រមែងចេញទៅ គឺរមែងរលាស់ចេញចាកលោក គឺវដ្តៈនេះ បានដល់ដល់ព្រះនិព្វាន ។

ក្នុងវេលាចប់ទេសនា ជនជាច្រើន សំរេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។l៚

( រឿងភិក្ខុ ៣០ រូប ចប់ )

******************

# ៩ រឿងនាងចិញ្ចមាណវិកា

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងជេតពន ទ្រង់ប្រារព្ធនាងចិញ្ចមាណវិកា ត្រាស់ព្រះធម្មទេសនានេះថា “**ឯកំ ធម្មំ អតីតស្ស**” ជាដើម ។

## ពួកតិរ្ថិយ៍ឫស្យាព្រះពុទ្ធសាសនា

សេចក្ដីពិស្ដារថា ក្នុងបឋមពោធិកាល កាលសាវកព្រះទសពល មានប្រមាណច្រើន, ពួកទេវតា និងពួកមនុស្សយោងចុះកាន់អរិយភូមិ, ការកើតឡើងនៃព្រះគុណរបស់ព្រះសាស្ដាបានផ្សព្វផ្សាយទៅ, ទើបលាភសក្ការៈជាច្រើនបានកើតឡើង ។ ពួកតិរ្ថិយ៍ប្រាកដដូចជាពន្លឺអំពិលអំពែក ក្នុងពេលព្រះអាទិត្យរះ ជាអ្នកសាបសូន្យលាភសក្ការៈ ។ ពួកតិរ្ថិយ៍ទាំងនោះ ឈរកណ្ដាលផ្លូវ ប្រកាសឲ្យពួកមនុស្សដឹងច្បាស់យ៉ាងនេះថា ព្រះសមណគោតមប៉ុណ្ណោះឬ ជាព្រះពុទ្ធ, សូម្បីយើងក៏ជាព្រះពុទ្ធដែរ, ទានដែលឲ្យដល់ព្រះសមណគោតមប៉ុណ្ណោះឬ មានផលច្រើន, សូម្បីទានដែលឲ្យហើយដល់ពួកយើង ក៏មានផលច្រើន

ដូចគ្នាដែរ, អ្នកទាំងឡាយចូរឲ្យ ចូរធ្វើដល់ពួកយើងខ្លះ មិនបានលាភសក្ការៈ ក៏ប្រជុំគ្នាក្នុងទីស្ងាត់ថា ពួកយើងគប្បីញុំាងទោសឲ្យកើតឡើងដល់ព្រះសមណគោតម ក្នុងរវាងមនុស្សទាំងឡាយ គប្បីញុំាងលាភសក្ការៈឲ្យវិនាសដោយឧបាយដូចម្ដេចហ្ន៎ ? កាលនោះក្នុងក្រុងសាវត្ថី មាននាងបរិព្វាជិកាម្នាក់ឈ្មោះចិញ្ចមាណវិកា ជាអ្នកមានរូបឆោមល្អ ដល់ការប្រសើរដោយកាពល្អ ដូចនាងទេពអប្សរដូច្នោះ, រស្មីបានផ្សាយចេញចាកសរីរៈរបស់នាង ។

# នាងចិញ្ចមាណវិកាទទួលអាសាពួកតិរ្ថិយ៍

លំដាប់នោះ តិរ្ថិយ៍អ្នកមានប្រាជ្ញាឈ្លាសវៃម្នាក់ ពោលយ៉ាងនេះថា ពួកយើងអាស្រ័យនាងចិញ្ចមាណវិកា គប្បីញុំាងទោសឲ្យកើតឡើងដល់ព្រះសមណគោតម ធ្វើលាភសក្ការៈរបស់លោកឲ្យវិនាសបាន ។ តិរ្ថិយ៍ទាំងនោះ ទទួលព្រមថាឧបាយនេះល្អ ។ តមក នាងចិញ្ចមាណវិកានោះ ទៅកាន់អារាមរបស់តិរ្ថិយ៍ ថ្វាយបង្គំហើយ ក៏បានឈរ ។ ពួកតិរ្ថិយ៍មិនតបតជាមួយនាង ។ ទើបនាងគិតថា យើងមានទោសអ្វីហ្ន៎ សូម្បីនាងនិយាយដល់ ៣ ដងថា លោកម្ចាស់ទាំងឡាយ នាងខ្ញុំ

ថ្វាយបង្គំ ហើយក៏និយាយថា លោកម្ចាស់ទាំងឡាយ នាងខ្ញុំមានទោសអ្វី ? ព្រោះហេតុអ្វី ទើបលោកម្ចាស់ទាំងឡាយមិននិយាយជាមួយនាងខ្ញុំ ?

តិរ្ថិយ៍. ម្នាលប្អូនស្រី នាងមិនដឹងថាព្រះសមណគោតមបៀតបៀនពួកយើង ត្រាច់ធ្វើពួកយើងឲ្យសាបសូន្យលាភសក្ការៈទេឬ ?

នាងចិ. នាងខ្ញុំមិនដឹងទេ លោកម្ចាស់, ចុះក្នុងរឿងនេះនាងខ្ញុំគួរធ្វើយ៉ាងណា ?

តិរ្ថិយ៍. ម្នាលប្អូនស្រី បើនាងប្រាថ្នាសេចក្តីសុខដល់ពួកយើង, ចូរញ៉ាំងទោសឲ្យកើតឡើង ដល់ព្រះសមណគោតមរួចញ៉ាំងលាភសក្ការៈឲ្យសាបសូន្យ ព្រោះអាស្រ័យខ្លួននាង ។ នាងពោលថា ល្អ លោកម្ចាស់ទាំងឡាយ, រឿងនេះចូរជាភារៈរបស់នាងខ្ញុំ,លោកម្ចាស់ទាំងឡាយកុំគិតឡើយ ហើយក៏ចៀសចេញទៅ ដណ្តប់សំពត់មានពណ៌ដូចសត្វមេភ្លៀង មានគ្រឿងក្រអូប និងកំរងផ្កាជាដើមក្នុងដៃ តម្រង់មុខឆ្ពោះវត្តជេតពនទៅក្នុងសម័យជាទីស្តាប់ធម្មកថា នៃអ្នកក្រុងសាវត្ថី ហើយចេញទៅអំពីវត្តជេតពនតាំងអំពីកាលនោះ ព្រោះសេចក្តីដែល

នាង ជាអ្នកធ្លាតក្នុងមាយារបស់ស្ត្រី, កាលអ្នកដទៃសួរនាងថា នាងទៅទីណាក្នុងវេលានេះ ? ក៏ពោលថា ប្រយោជន៍អ្វីរបស់ពួកលោក ដោយទីដែលខ្ញុំទៅ សំរាកក្នុងវត្តរបស់តិរិយ៍ជិតវត្តជេតពន កាលមនុស្សជាឧបាសកចេញអំពីព្រះនគរអំពីព្រលឹម ដោយសង្ឃឹមថា នឹងថ្វាយបង្គំព្រះសាស្ដា នាងធ្វើដូចជានៅក្នុងវត្តជេតពនចូលទៅកាន់ព្រះនគរ, កាលជនជាឧបាសកសួរថា នាងនៅទីណា ? ក៏ពោលថា ប្រយោជន៍អ្វីរបស់ពួកលោក ដោយទីដែលខ្ញុំនៅ ដោយកាលកន្លងទៅ ២-៣ ខែ កាលត្រូវគេសួរ ក៏ពោលថា ខ្ញុំនៅក្នុងព្រះគន្ធកុដិជាមួយព្រះសមណគោតម ក្នុងវត្តជេតពនញុំាងសេចក្ដីសង្ស័យដល់ពួកបុថុជ្ជនថា រឿងនុ៎ះពិត ឬមិនពិតហ្ន៎ ? ដោយកាលកន្លងទៅ ៣-៤ ខែ យកកំណាត់សំពត់ចងពោះ សំដែងភេទរបស់ស្ត្រីមានគភ៌ ឲ្យពួកជនអន្ធពាលប្រកាន់ជឿថា គភ៌កើតឡើងព្រោះអាស្រ័យព្រះសមណគោតម ដោយកាលកន្លងទៅ ៨-៩ ខែ ចងដុំឈើ មូលត្រង់ពោះ ដណ្ដប់សំពត់ពីលើ យកឆ្អឹងគោវាយដៃ និងជើង សំដែងអាការផើមមានឥន្ទ្រីយ៍មិនស្រស់បស់ កាលព្រះ

តថាគតប្រថាប់គង់សំដែងធម៌លើធម្មាសនៈ ដែលគេតាក់តែង ហើយ ក្នុងវេលារសៀល, ទៅកាន់ធម្មសភា ឈរខាងមុខព្រះ កក្រ្តហើយរបស់ព្រះសាស្តាហើយ ពោលថា មហាសមណៈ ព្រះអង្គល្អតែសំដែងធម៌ដល់មហាជនប៉ុណ្ណោះ, សំឡេងរបស់ ព្រះអង្គពីរោះ, ព្រះឱស្ឋរបស់ព្រះអង្គស្និទ្ធ, ចំណែកខ្ញុំម្ចាស់ អាស្រ័យព្រះអង្គ បានមានគភ៌គ្រប់កំណត់ហើយ, ព្រះអង្គមិន ទ្រង់ជ្រាបផ្ទះសំរាប់ប្រសូត មិនជ្រាបគ្រឿងបរិហារគភ៌ មាន ទឹកដោះថ្លា និងទឹកឃ្មុំជាដើម, បើមិនទ្រង់ធ្វើខ្លួនឯង ម្តេចមិន ត្រាស់ប្រាប់ព្រះបាទកោសល ឬអនាថបិណ្ឌិក ឬក៏នាងវិសាខា មហាឧបាសិកាណាមួយ បណ្តាឧបដ្ឋាកទាំងឡាយថា អ្នកចូរ ធ្វើកិច្ចដែលគួរធ្វើដល់នាងចិញ្ចមាណវិកានេះ, ព្រះអង្គទ្រង់ដឹង តែអភិរម្យប៉ុណ្ណោះ, មិនទ្រង់ដឹងការរក្សាគភ៌, ( នាងចិញ្ចមាណ វិកា ) ដូចព្យាយាមចាប់ដុំលាមក គប់មណ្ឌលព្រះច័ន្ទដូច្នោះ បានជេរព្រះតថាគតកណ្តាលបរិស័ទ ។ ព្រះតថាគត ទ្រង់ផ្អាក ធម្មកថាហើយ ទ្រង់បន្លឺសំរែកសីហៈថា ប្អូនស្រី ពាក្យដែល នាងពោលហើយ នឹងពិត ឬមិនពិត មានតែតថាគត និងនាង ប៉ុណ្ណោះដឹង ។

នាងចិញ្ចមាណវិកា. ត្រូវហើយ មហាសមណៈ រឿង នុ៎ះ កើតឡើងដោយព្រះអង្គ និងខ្ញុំម្ចាស់ជាអ្នកជ្រាប ។

## ទេវបុត្រទំលាយកលឧបាយរបស់នាងចិញ្ចមាណវិកា

ខណៈនោះ អាសនៈរបស់សក្កទេវរាជ សំដែងអាការក្តៅ ។ ព្រះអង្គពិចារណាមើលក៏ជ្រាបថា នាងចិញ្ចមាណវិកាជេរព្រះតថាគតដោយពាក្យមិនពិត ហើយទ្រង់តម្រិះទៀតថា យើងនឹងជំរះរឿងនេះឲ្យហ្មត់ចត់ ទើបស្តេចមកជាមួយនឹងទេវបុត្រ ៤ អង្គ ។ ទេវបុត្រទាំងឡាយ ក្លែងជាកណ្តុរខាំខ្សែដែលចងដុំឈើមូល ដោយខាំតែមួងប៉ុណ្ណោះ ។ ខ្យល់ផាត់ផ្ទាំងសំពត់ដណ្តប់ឡើង ។ ឈើមូលរបូតធ្លាញ់ចុះលើខ្នងជើងរបស់នាងចិញ្ចមាណវិកានោះ ។ ចុងជើងទាំងពីរខាងបានបែក ។ មនុស្សទាំងឡាយនិយាយថា នែនាងកាឡកណ្ណី នាងជេរព្រះសម្មាសម្ពុទ្ធ ហើយបានស្តោះទឹកមាត់លើក្បាល មានដៃកាន់ដុំដី និងដំបង បណ្តេញនាងចេញចាកវត្តជេតពន ។

## នាងចិញ្ចមាណវិកាត្រូវផែនដីស្រូប

ពេលដែលនាងទៅផុតគន្លងព្រះនេត្ររបស់ព្រះតថាគតទៅ មហាផែនដីបែករបែកចំហមាត់ចាំ ។ អណ្តាតភ្លើងតាំង

ឡើងអំពីអវិចីនរក ។ នាងចិញ្ចមាណវិកានោះ ទៅកើតក្នុងអវិចី ដូចជាដណ្តប់សំពត់កម្ពលដែលត្រកូលឲ្យ ។ លាភ-សក្ការៈរបស់ពួកតិរ្ថិយ៍បានសាបសូន្យ ។ ត្រឡប់ជាចំរើនដល់ព្រះទសពលប្រមាណក្រៃលែង ។

ក្នុងថ្ងៃព្រឹកឡើង ពួកភិក្ខុសន្ទនាគ្នាក្នុងធម្មសភាថា អ្នកមានអាយុទាំងឡាយ នាងចិញ្ចមាណវិកាជេរព្រះសម្មាសម្ពុទ្ធជាអគ្គទក្ខិណេយ្យ អ្នកមានគុណប្រមាណមិនបានយ៉ាងនេះដោយពាក្យមិនពិត ទើបដល់មហាវិនាស ។ ព្រះសាស្ដាស្ដេចមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយពាក្យពេចន៍អ្វី ? កាលភិក្ខុទាំងឡាយក្រាបទូលថា ដោយពាក្យឈ្មោះនេះ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវនេះទេ, ក្នុងកាលមុន នាងចិញ្ចមាណវិកានោះ ក៏ជេរតថាគតដោយពាក្យមិនពិត ដល់សេចក្ដីវិនាសដូចគ្នាដែរ ហើយត្រាស់មហាបទុមជាតក ក្នុងទ្វាទសកនិបាតនេះ ឲ្យពិស្ដារថា ៖

អ្នកជាធំ មិនឃើញទោសតូច-ធំ របស់អ្នកដទៃ
ដោយប្រការទាំងពួងហើយ មិនទាន់ពិចារណាខ្លួន

៦៨ មិនគប្បីដាក់អាជ្ញា ។

## ព្រះពោធិសត្វត្រូវទំលាក់ចុះក្នុងជ្រោះតែមិនស្លាប់

( ព្រះអង្គត្រាស់ថា ) បានឮថា ក្នុងកាលនោះ នាងចិញ្ចមាណវិកានោះ ជាអ្នករួមស្វាមីរបស់ព្រះមាតានៃព្រះពោធិសត្វ ព្រះនាមថា មហាបទុមកុមារ ជាអគ្គមហេសីរបស់ព្រះរាជា បបួលព្រះមហាសត្វដោយអសទ្ធម្ម មិនបានការយល់ព្រមរបស់ព្រះពោធិសត្វនុ៎ះហើយ ធ្វើប្រការប្លែកក្នុងខ្លួនដោយខ្លួនឯង សំដែងអាការជាឈឺ ក្រាបទូលដល់ព្រះរាជាថា ព្រះឱរសរបស់ព្រះអង្គ ធ្វើឲ្យខ្ញុំម្ចាស់ដែលមិនប្រាថ្នា ដល់ប្រការប្លែកនេះ ។ ព្រះរាជាទ្រង់ខ្ញាល់ ទំលាក់ព្រះពោធិសត្វទៅក្នុងជ្រោះ ដែលសំរាប់ទំលាក់ចោរ ។

គ្រានោះ ទេវតាដែលអាស្រ័យនៅត្រង់ផ្ទៃនៃភ្នំ ( ជ្រោះ ) ទទួលព្រះមហាសត្វនោះហើយ ឲ្យប្រតិស្ឋានទៅក្នុងផ្ទៃពពាររបស់ស្តេចនាគ ។ ស្តេចនាគនាំព្រះមហាសត្វនោះទៅកាន់ភពនាគ ទ្រង់រាប់អានដោយរាជសម្បត្តិពាក់កណ្តាល ។ ព្រះមហាសត្វនោះនៅក្នុងភពនាគអស់មួយឆ្នាំ ប្រាថ្នានឹងបួស ក៏មកកាន់

ហិមវន្តប្រទេស បួសហើយ ក៏បានញុំាងឈាន និងអភិញ្ញាឲ្យកើតឡើង ។

## ព្រះពោធិសត្វថ្វាយព្រះឱវាទដល់ព្រះរាជា

តមក ព្រានព្រៃម្នាក់ឃើញព្រះមហាសត្វនោះ ក៏បានក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាស្ដេចទៅកាន់សំណាក់របស់ព្រះពោធិសត្វនោះហើយ មានបដិសណ្ឋារៈដែលព្រះពោធិសត្វនោះធ្វើហើយ ទ្រង់បានជ្រាបព្រឹត្តិហេតុនោះទាំងអស់ ទ្រង់បានអញ្ជើញព្រះមហាសត្វដោយរាជសម្បត្តិ ព្រះមហាសត្វនោះថ្វាយព្រះឱវាទថា កិច្ចដោយរាជសម្បត្តិរបស់ខ្ញុំព្រះអង្គមិនមាន, ក៏ព្រះអង្គចូរកុំឲ្យរាជធម៌ ១០ ប្រការកំរើក ទ្រង់លះអគតិចេញហើយ សោយរាជ្យដោយធម៌ចុះ ហើយស្ដេចក្រោកពីអាសនៈ ទ្រង់ព្រះកន្សែង ស្ដេចទៅកាន់ព្រះនគរ ត្រាស់សួរអាមាត្យទាំងឡាយពាក់កណ្ដាលផ្លូវថា យើងដល់ការព្រាត់ប្រាសចាកបុត្រដែលសម្បូណ៌ដោយអាចារយ៉ាងនេះ ព្រោះអាស្រ័យនរណា ?

អាមាត្យ. បពិត្រព្រះអង្គ ព្រោះអាស្រ័យអគ្គមហេសី ។

ព្រះរាជាត្រាស់ឲ្យចាប់ព្រះអគ្គមហេសីនោះ ឲ្យមានជើងឡើងលើ ទំលាក់ទៅក្នុងជ្រោះសំរាប់ទំលាក់ចោរ ស្ដេចចូល

ទៅកាន់ព្រះនគរ សោយរាជសម្បត្តិដោយធម៌ ។ ព្រះមហាបទុមកុមារក្នុងកាលនោះ បានមកជាព្រះមហាសត្វ, ស្ត្រីរួមស្វាមីរបស់ព្រះមាតា បានមកជានាងចិញ្ចមាណវិកា ។

ព្រះសាស្តា ទ្រង់ប្រកាសសេចក្តីនេះហើយ មានព្រះពុទ្ធដីកាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលលះពាក្យសត្យដែលជាធម៌ឯកហើយ តាំងនៅក្នុងមុសាវាទ អ្នកមានបរលោកលះហើយ មិនធ្វើបាបកម្មមិនមានឡើយ ហើយត្រាស់ព្រះគាថានេះថា ៖

**៩ ឯកំ ធម្មំ អតីតស្ស មុសាវាទិស្ស ជន្តុនោ**
**វិតិណ្ណបរលោកស្ស នត្ថិ បាបំ អការិយំ ។**

បុគ្គលប្រព្រឹត្តកន្លង ( ពាក្យសច្ចៈ ) ដែលជាធម៌ឯក និយាយតែពាក្យកុហក មានបរលោកលះចោលហើយ ឈ្មោះថាមិនធ្វើអំពើបាប មិនមែនឡើយ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **ឯកំ ធម្មំ** គឺនូវពាក្យសត្យ ។ បទថា **មុសាវាទិស្ស** សេចក្តីថា បណ្តាពាក្យនិយាយទាំង១០ ពាក្យសត្យសូម្បីតែ ១ មិនមានដល់អ្នកណា, អ្នក

បែបនេះ ឈ្មោះថាអ្នកនិយាយតែពាក្យកុហក ។ បាទព្រះគាថាថា **វិតិណ្ណបរលោកស្ស** បានដល់ អ្នកមានបរលោកដែលលះចោលហើយ, ក៏បុគ្គលបែបនេះ រមែងមិនប្រទះសម្បត្តិទាំង ៣ នេះ គឺមនុស្សសម្បត្តិ ទេពសម្បត្តិ និព្វានសម្បត្តិក្នុងអវសានឡើយ ។ ពីរបទថា **នត្ថិ បាបំ** សេចក្តីថា សេចក្តីសង្ស័យថា បាបឈ្មោះនេះ ដែលបុគ្គលនោះ គឺអ្នកបែបនោះ មិនគប្បីធ្វើ មិនមានសោះឡើយ ។

ក្នុងវេលាចប់ទេសនា ជនជាច្រើន សំរេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

( រឿងនាងចិញ្ចមាណវិកា ចប់ )

*********************

# ១០ រឿងអសទិសទាន

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអសទិសទាន ត្រាស់ព្រះធម្មទេសនានេះថា “**ន វេ កទរិយា ទេវលោកំ វជន្តិ**” ជាដើម ។

## ព្រះរាជាថ្វាយទានប្រជែងជាមួយនឹងរាស្ត្រ

សេចក្ដីពិស្ដារថា សម័យមួយ ព្រះសាស្ដាស្ដេចចារិកទៅមានភិក្ខុប្រមាណ ៥០០ ជាបរិវារ ស្ដេចចូលទៅក្នុងវត្តជេតពន ។ ព្រះរាជាស្ដេចទៅវិហារ និមន្តព្រះសាស្ដាក្នុងថ្ងៃព្រឹកឡើង ទ្រង់ចាត់ចែងអាគន្តុកទានហើយ ត្រាស់ហៅអ្នកនគរថា ចូរមើលទានរបស់យើង ។ អ្នកនគរមកឃើញទានរបស់ព្រះរាជាហើយ ក្នុងថ្ងៃព្រឹកឡើង ទូលនិមន្តព្រះសាស្ដាចាត់ចែងទានហើយ បញ្ជូនដំណឹងទៅក្រាបទូលដល់ព្រះរាជាថា សូមព្រះអង្គទ្រង់ជាសម្មតិទេព សូមទតព្រះនេត្រទានរបស់ពួកខ្ញុំព្រះអង្គ ។ ព្រះរាជាស្ដេចទៅទតព្រះនេត្រទានរបស់ពួកអ្នកនគរនោះហើយ ទ្រង់តម្រិះថា ជនទាំងនេះធ្វើទានក្រៃលែង ជាង

ទានរបស់យើង, យើងនឹងធ្វើទានទៀត ទើបត្រាស់ឲ្យចាត់ចែតទានក្នុងថ្ងៃព្រឹកឡើងទៀត ។ សូម្បីពួកអ្នកនគរឃើញទាននោះហើយ ក្នុងថ្ងៃព្រឹកឡើង ក៏ចាត់ចែងទានដោយប្រការដូច្នេះ ។ ដោយអាការយ៉ាងនេះឯង ព្រះរាជាមិនទ្រង់អាចដើម្បីឲ្យអ្នកនគរចាញ់បានឡើយ ពួកអ្នកនគរក៏មិនអាចដើម្បីនឹងឲ្យព្រះរាជាចាញ់បាន ។ តមក ក្នុងវារៈទី ៦ អ្នកនគរប្រឹក្សាគ្នាថាចាត់ចែងទានដោយប្រការដែលនរណាៗ មិនអាចនិយាយបានថា វត្ថុនេះមិនមានក្នុងទានរបស់អ្នកនគរទាំងនេះ, ព្រះរាជាទតព្រះនេត្រទាននោះហើយ ទ្រង់តម្រិះថា បើយើងមិនអាចដើម្បីធ្វើទាន ឲ្យក្រៃលែងជាងទានរបស់អ្នកនគរទាំងនោះសោត, ប្រយោជន៍អ្វីរបស់យើងដោយការរស់នៅ ដូច្នេះហើយ បានផ្ទំត្រិះរិះរកឧបាយ ។

# ព្រះនាងមល្លិកាចាត់ចែងទាន

លំដាប់នោះ ព្រះនាងមល្លិកាទេវី ចូលទៅគាល់ព្រះអង្គហើយ ទូលសួរថា បពិត្រមហារាជ ហេតុអ្វីបានជាព្រះអង្គផ្ទំយ៉ាងនេះ ព្រះរាជាត្រាស់ថា ទេវី ឥឡូវនេះ នាងនៅមិនទាន់ជ្រាបទេឬ ?

ព្រះទេវី. ខ្ញុំម្ចាស់មិនជ្រាបទេ ព្រះអង្គ ។

ព្រះអង្គក៏បានត្រាស់ប្រាប់សេចក្តីនោះដល់ព្រះនាង ។

លំដាប់នោះ ព្រះនាងមល្លិកាក្រាបទូលព្រះអង្គថា បពិត្រព្រះសម្មតិទេព ព្រះអង្គកុំទ្រង់ត្រិះរិះឡើយ, ព្រះរាជាជាធំក្នុងផែនដី ត្រូវពួកអ្នកនគរផ្ចាញ់បាន ព្រះអង្គធ្លាប់ទតព្រះនេត្រឃើញឬ ឬធ្លាប់សណ្តាប់ហើយនៅទីណា ? ខ្ញុំម្ចាស់នឹងចាត់ចែងទានជំនួសព្រះអង្គ ។

ព្រះនាងក្រាបទូលដល់ព្រះអង្គយ៉ាងនេះ ព្រោះសេចក្តីដែលព្រះនាងជាអ្នកប្រាជ្ញានឹងចាត់ចែងអសទិសទាន ហើយក្រាបទូលថា បពិត្រព្រះមហារាជ សូមព្រះអង្គបញ្ជាឲ្យគេធ្វើមណ្ឌបសំរាប់គង់ខាងក្នុងរង្វង់មូល ដើម្បីភិក្ខុប្រមាណ ៥០០ រូប ដោយទោបដែលធ្វើដោយសាលៈ និងដើមក្ងៅនាង ពួកភិក្ខុដ៏សេសនឹងគង់ខាងក្រៅរង្វង់មូល, សូមបញ្ជាឲ្យធ្វើស្វេតច្ឆត្រ ៥០០, ដំរីប្រមាណ ៥០០ នឹងកាន់ស្វេតច្ឆត្រទាំងនោះឈរបាំងខាងលើភិក្ខុប្រមាណ ៥០០ រូប, សូមត្រាស់បញ្ជាឲ្យធ្វើទូកដែលសំរេចដោយមាស ដែលមានពណ៌ក្រហម ៨-១០, ទូកទាំងនោះនឹងមានកណ្តាលមណ្ឌប, ខត្តិយធីតាមួយអង្គៗ នឹង

កាន់ផ្ចិតឈរបក់ភិក្ខុ ២ រូបៗ, ខត្តិយធីតាដ៏សេសនឹងនាំរបស់ក្រអូបដែលអប់ហើយៗ មកដាក់ក្នុងទូកមាសទាំងឡាយ, បណ្ដាខត្តិយធីតាទាំងនោះ ខត្តិយធីតាពួកខ្លះ នឹងកាន់បាច់ផ្កាឧប្បលទៀត លាយរបស់ក្រអូបទុកក្នុងទូកមាសហើយ នឹងប្រោសព្រំភិក្ខុ, ព្រោះខត្តិយធីតាមិនមានដល់ពួកអ្នកនគរឡើយ, សេ្វតច្ឆត្រក៏មិនមាន ដំរីក៏មិនមាន, ពួកអ្នកនគរនឹងចាញ់ដោយហេតុទាំងនេះ, បពិត្រមហារាជ សូមព្រះអង្គត្រាស់ឲ្យធ្វើយ៉ាងនេះចុះ ។ ព្រះរាជាព្រមទទួលថា ល្អ ព្រះទេវី រឿងល្អនាងបានប្រាប់ហើយ ក៏ត្រាស់ឲ្យធ្វើកិច្ចទាំងអស់ តាមទំនងដែលព្រះនាងក្រាបទូលហើយ ។ ក៏ដំរី ១ នៅមិនគ្រប់ដល់ភិក្ខុមួយរូប ។

លំដាប់នោះ ព្រះរាជាត្រាស់នឹងព្រះនាងមល្លិកាថា នាងដ៏ចំរើន ដំរី ១ នៅមិនគ្រប់ដល់ភិក្ខុមួយរូប, យើងនឹងធ្វើដូចម្ដេច ?

ព្រះទេវី. ដំរី ៥០០ មិនមានឬ ព្រះអង្គ ?

ព្រះរាជា. មាន ទេវី, តែដំរីដ៏សេស ជាដំរីកាច, ដំរីទាំងនោះគ្រាន់តែឃើញភិក្ខុទាំងឡាយចូល ជាសត្វកាចដូចខ្យល់កំបុតត្បូង ។

ព្រះទេវី. បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់ជ្រាបទីសំរាប់ឈរកាន់ឆត្ររបស់កូនដំរីកាចមួយ ។

ព្រះរាជា. យើងនឹងយកដំរីឈរទីណា ?

ព្រះទេវី. ឈរជិតព្រះអង្គុលិមាលត្ថេរ ។

ព្រះរាជា ក៏បានត្រាស់ឲ្យរាជបុរសធ្វើដូច្នោះ ។ កូនដំរីស៊កកន្ទុយចូលក្នុងចន្លោះភ្លៅ បានទំលាក់ត្រចៀកទាំងពីរ ឈរធ្មេចភ្នែក ។ មហាជនក្រឡេកមើលដំរី ដែលទ្រង់ស្វេតច្ឆត្រដើម្បីព្រះថេរៈប៉ុណ្ណោះ ដោយគិតថា នេះជាអាការរបស់ដំរីកាចបែបនេះ ព្រះអង្គុលិមាលត្ថេរធ្វើបាន ។ ព្រះរាជា ទ្រង់អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយអាហារដ៏ប្រណីតហើយ ថ្វាយបង្គំព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន វត្ថុណាជាកប្បិយភណ្ឌ ឬជាអកប្បិយភណ្ឌក្នុងរោងទាននេះ ខ្ញុំព្រះអង្គនឹងថ្វាយវត្ថុនោះទាំងអស់ដល់ព្រះអង្គប៉ុណ្ណោះ។ ទានដែលព្រះនាងមល្លិកាចាត់ចែងឈ្មោះថាអសទិសទាន

ក៏ក្នុងទាននោះឯង ទ្រព្យមានប្រមាណ ១៤ កោដិ ជាទ្រព្យដែលព្រះរាជាទ្រង់បរិច្ចាគមួយថ្ងៃប៉ុណ្ណោះ ។ ក៏របស់ ៤ យ៉ាង គឺស្វេតច្ឆត្រ ១ បល្លង្កសំរាប់គង់ ១ ជើងបាត្រ ១ តាំង

សំរាប់ជូតជើង ១ ជារបស់កាត់ថ្លៃមិនបាន ដើម្បីព្រះសាស្ដា ។ នរណាៗ ដែលអាចធ្វើទានបែបនេះហើយ ថ្វាយទានដល់ព្រះពុទ្ធទាំងឡាយ មិនមានទៀតឡើយ ។ ព្រោះហេតុនោះឯង ទើបទាននោះឈ្មោះថា **អសទិសទាន** ។ បានឮថា អសទិសទាននោះ មានសំរាប់ព្រះពុទ្ធគ្រប់ៗ ព្រះអង្គតែម្ដងប៉ុណ្ណោះ ។ ស្ត្រីប៉ុណ្ណោះ រមែងចាត់ចែងទានដើម្បីព្រះសាស្ដា និងភិក្ខុទាំងពួង ។

## លក្ខណះរបស់មនុស្សល្អមនុស្សអាក្រក់

ក៏អាមាត្យរបស់ព្រះរាជាមាន ២ នាក់ គឺកាឡៈ ១ ជុណ្ហៈ ១ ។ បណ្ដាអាមាត្យទាំង ២ នោះ កាឡអាមាត្យគិតថា ឱ ! សេចក្ដីវិនាសនៃរាជត្រកូល, ទ្រព្យ ១៤ កោដិដល់ការអស់ទៅត្រឹមមួយថ្ងៃប៉ុណ្ណោះ, ភិក្ខុទាំងនេះបរិភោគទានហើយ នឹងទៅដេក, ឱ ! រាជត្រកូលវិនាសហើយ ។ ចំណែកជុណ្ហអាមាត្យគិតថា ឱ ! ទានរបស់ព្រះរាជា, ក៏នរណាៗ មិនតាំងនៅក្នុងភាពជាព្រះរាជា មិនអាចដើម្បីថ្វាយទានបែបនេះបានទេ ។ ព្រះរាជាឈ្មោះថាមិនឲ្យចំណែកបុណ្យ ដល់សត្វទាំងពួង រមែងមិនមាន, យើងអនុមោទាននេះ ។

ក្នុងទីបំផុតកត្តកិច្ចនៃព្រះសាស្តា ព្រះរាជាទ្រង់ទទួលបាត្រដើម្បីត្រូវការអនុមោទនា ។ ព្រះសាស្តា ទ្រង់ត្រិះរិះថា ព្រះរាជាថ្វាយមហាទាន ដូចឲ្យអន្ទង់ទឹកជំប្រព្រឹត្តទៅ ។ មហាជនអាចដើម្បីញ៉ាំងចិត្តឲ្យជ្រះថ្លា ឬមិនជ្រះថ្លាហ្ន៎ ? ព្រះអង្គទ្រង់ជ្រាបវារៈចិត្តរបស់អាមាត្យទាំងនោះហើយ ទ្រង់ជ្រាបថា បើតថាគតនឹងធ្វើអនុមោទនាឲ្យសមគួរដល់ទានរបស់ព្រះរាជា សោត, សីសៈរបស់កាឡអាមាត្យនឹងបែកជា ៧ ចំរៀក, ជុណ្ហអាមាត្យនឹងតាំងនៅក្នុងសោតាបត្តិផល ទ្រង់អាស្រ័យសេចក្តីអនុគ្រោះក្នុងកាលអាមាត្យ ទើបត្រាស់ព្រះគាថា ៤ បាទប៉ុណ្ណោះ ដល់ព្រះរាជាដែលទ្រង់ថ្វាយទានបែបនេះ ប្រថាប់ឈរហើយ ស្តេចក្រោកអាសនៈទៅកាន់ព្រះវិហារ ។

## ត្រាស់សរសើរព្រះអង្គុលិមាល

ភិក្ខុទាំងឡាយសួរព្រះអង្គុលិមាលត្ថេរថា អ្នកមានអាយុលោកឃើញដំរីកាចឈរបាំងឆត្រ មិនខ្លាចទេឬ ?

ព្រះអង្គុលិ. អ្នកមានអាយុទាំងឡាយ ខ្ញុំមិនខ្លាចទេ ។

ភិក្ខុទាំងនោះ ចូលទៅគាល់ព្រះសាស្តាហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គុលិមាលព្យាករអរហត្តផល ។

ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អន្តលិមាលមិនខ្វាច ទេ, ព្រោះថា ភិក្ខុទាំងឡាយ ជាអ្នកប្រាកដស្មើដូចជាបុត្រ តថាគត ប្រាកដស្មើដោយគោដ៏ប្រសើរ ក្នុងចន្លោះនៃគោ គឺ ព្រះខីណាស្រពទាំងឡាយ រមែងមិនខ្វាច ហើយទ្រង់ត្រាស់ ព្រះគាថាក្នុងព្រាហ្មណវគ្គថា ៖

តថាគតហៅវីរបុរស អ្នកអង់អាច អ្នកប្រសើរ
អ្នកស្វែងរកគុណដ៏ធំ ឈ្នះមារ មិនមានកិលេសជា
គ្រឿងញាប់ញ័រ ងូតលាងកិលេស ត្រាស់ដឹងសច្ចៈ
នោះ ថាជាព្រាហ្មណ៍ ។

ចំណែកព្រះរាជាដល់សេចក្ដីទោមនស្សថា ព្រះសាស្ដា មិនទ្រង់ធ្វើអនុមោទនា ឲ្យសមគួរដល់យើង ដែលថ្វាយទាន ហើយ ឈរនៅក្នុងកណ្ដាលបរិស័ទបែបនេះ ត្រាស់ត្រឹមតែ ព្រះគាថាប៉ុណ្ណោះ ហើយស្ដេចក្រោកចាកអាសនៈទៅ, យើង នឹងជាអ្នកដែលមិនធ្វើទាន ឲ្យសមគួរដែលព្រះសាស្ដា ធ្វើទាន ដែលមិនសមគួរ, យើងនឹងជាអ្នកមិនថ្វាយកប្បិយភណ្ឌ ថ្វាយ តែអកប្បិយភណ្ឌប៉ុណ្ណោះ, យើងនឹងជាអ្នកដែលព្រះសាស្ដា ទ្រង់មិនពេញព្រះទ័យ, ការធ្វើអនុមោទនាដ៏សមគួរដល់ទាន

របស់អ្នកណាមួយនុ៎ះឯងទើបគួរ ហើយស្ដេចចូលទៅកាន់វិហារ ថ្វាយបង្គំព្រះសាស្ដាហើយ បានក្រាបទូលពាក្យនេះថា បពិត្រព្រះអង្គដ៏ចំរើន ទានដែលគួរនឹងថ្វាយ ខ្ញុំព្រះអង្គមិនបានថ្វាយឬ ឬខ្ញុំព្រះអង្គមិនបានថ្វាយកប្បិយភណ្ឌដ៏សមគួរដល់ទាន ថ្វាយតែអកប្បិយភណ្ឌប៉ុណ្ណោះ ?

ព្រះសាស្ដា. នេះដូចម្ដេច មហាបពិត្រ ?

ព្រះរាជា. ព្រះអង្គមិនទ្រង់ធ្វើអនុមោទនា ដ៏សមគួរដល់ទានរបស់ខ្ញុំព្រះអង្គ ។

ព្រះសាស្ដា. មហាបពិត្រ ព្រះអង្គថ្វាយទានដ៏សមគួរហើយ ក៏ទាននោះឈ្មោះថាអសទិសទាន, នរណាៗ អាចដើម្បីថ្វាយដល់ព្រះពុទ្ធអង្គម្ដងប៉ុណ្ណោះ, ធម្មតាទានបែបនេះ ជារបស់លំបាក ដែលបុគ្គលនឹងថ្វាយទាន ។

ព្រះរាជា. បពិត្រព្រះអង្គដ៏ចំរើន បើដូច្នោះ ព្រោះហេតុអ្វី ទើបព្រះអង្គមិនធ្វើអនុមោទនា ឲ្យសមគួរដល់ទានរបស់ខ្ញុំព្រះអង្គ ?

ព្រះសាស្ដា. ព្រោះបរិស័ទមិនបរិសុទ្ធ មហាបពិត្រ ។

ព្រះរាជា. បពិត្រព្រះអង្គដ៏ចំរើន ទាស់ដូចម្តេចរបស់បរិស័ទ ?

## ព្រះរាជានិរទេសអាមាត្យអាក្រក់

លំដាប់នោះ ព្រះសាស្តា ត្រាស់ប្រាប់វារៈចិត្តរបស់អាមាត្យទាំងពីរហើយ ត្រាស់ប្រាប់ការអនុមោទនា ជាការដែលព្រះអង្គអាស្រ័យសេចក្តីអនុគ្រោះ ក្នុងកាឡអាមាត្យ ទើបមិនទ្រង់ធ្វើហើយដល់ព្រះរាជា ។ ព្រះរាជាត្រាស់សួរថា កាឡៈបានឮថា លោកគិតយ៉ាងនេះពិតមែនឬ ? កាលកាឡអាមាត្យក្រាបទូលថា ពិត ទើបត្រាស់ថា យើង ព្រមទាំងបុត្រភរិយារបស់យើង មិនបានកាន់យកទ្រព្យសម្បត្តិរបស់អ្នក ឲ្យទ្រព្យសម្បត្តិរបស់ខ្លួនទេ, បៀតបៀនអ្វីអ្នក ? វត្ថុណាដែលយើងឲ្យដល់អ្នកហើយ វត្ថុនោះ ចូរជាការដែលឲ្យហើយ, តែអ្នកចូរចេញចាកដែនរបស់យើង ហើយទ្រង់និរទេសនាយកាឡៈនោះចេញចាកដែន ហៅត្រាស់ឲ្យហៅជុណ្ហអាមាត្យមកសួរថា បានឮថា អ្នកគិតយ៉ាងនេះពិតមែនឬ ? កាលជុណ្ហអាមាត្យក្រាបទូលថា ពិត ក៏ត្រាស់ថា ល្អ យើងជ្រះថ្លា, អ្នកចូរទទួលរាជសម្បត្តិរបស់យើង ហើយឲ្យទាន ៧ ថ្ងៃ តាមទំនងដែលយើង

ឲ្យហើយនោះឯង ទ្រង់ប្រគល់រាជសម្បត្តិ ដល់ជុណ្ហអាមាត្យអស់ ៧ ថ្ងៃហើយ ក៏ក្រាបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គទតព្រះនេត្រ ការធ្វើរបស់ជនពាល, គេបានឲ្យការប្រហារក្នុងទាន ដែលខ្ញុំព្រះអង្គថ្វាយហើយយ៉ាងនេះ ។

## មនុស្សកំណាញ់ទៅទេវលោកមិនបាន

ព្រះសាស្តា ត្រាស់ថា ពិតមែន មហាបពិត្រ, ឈ្មោះថាពួកជនពាល មិនត្រេកអរទានរបស់អ្នកដទៃ ជាអ្នកមានទុគ្គតិជាទីទៅខាងមុខ, ចំណែកពួកអ្នកប្រាជ្ញ អនុមោទនាទានរបស់ពួកជនដទៃ ទើបជាអ្នកមានសួគ៌ ជាទីទៅខាងមុខដោយពិត ហើយត្រាស់ព្រះគាថានេះថា ៖

**១០ ន វេ កទរិយា ទេវលោកំ វជន្តិ**
**ពាលា ហវេ នប្បសំសន្តិ ទានំ**
**ធីរោ ច ទានំ អនុមោទមានោ**
**តេនេវ សោ ហោតិ សុខី បរត្ថ ។**

បុគ្គលកំណាញ់ស្វិតស្វាញ មិនបានទៅកាន់ទេវលោកទេ ជនពាលទាំងឡាយ មិនសរសើរ

ទានឡើយ ចំណែកអ្នកប្រាជ្ញ តែងអនុមោទាន ព្រោះហេតុនោះ លោកតែងបានសេចក្តីសុខក្នុង លោកខាងមុខ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **កទរិយា** គឺអ្នកមានសេចក្តីកំណាញ់ស្វិតស្វាញ ។ អ្នកមិនដឹងប្រយោជន៍លោកនេះ និងលោកខាងមុខ ឈ្មោះថា ពាលទាំងឡាយ ។ បណ្ឌិត ឈ្មោះថា ធីរជន ។ ពីរបទថា **សុខី បរត្ថ** សេចក្តីថា ធីរជននោះ កាលសោយទិព្វសម្បត្តិ ឈ្មោះថា ជាអ្នកមានសេចក្តីសុខក្នុងលោកខាងមុខ ព្រោះបុណ្យ ដែលសំរេចអំពីការអនុមោទនាទាននោះនុ៎ះឯង ។

ក្នុងវេលាចប់ទេសនា ជុណ្ហអាមាត្យតាំងនៅក្នុងសោតាបត្តិផល ។ ទេសនាបានមានប្រយោជន៍សូម្បីដល់បរិស័ទដែលប្រជុំគ្នា ។ ជុណ្ហអាមាត្យ ពេលជាព្រះសោតាបន្នហើយ បានថ្វាយទានដោយទំនង ដែលព្រះរាជាថ្វាយហើយ អស់ ៧ ថ្ងៃដូចគ្នា ដូច្នោះឯង ។៚

( រឿងអសទិសទាន ចប់ )

# ១១ រឿងនាយកាឡសេដ្ឋីបុត្រ

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងជេតពន ទ្រង់ប្រារព្ធបុត្ររបស់អនាថបិណ្ឌិកសេដ្ឋីឈ្មោះ កាឡៈ ត្រាស់ព្រះធម្មទេសនានេះថា “**បឋព្យា ឯករជ្ជេន**” ជាដើម ។

## បិតាជួលបុត្រឲ្យស្តាប់ធម៌

បានឮថា នាយកាឡៈនោះជាបុត្រសេដ្ឋី អ្នកដល់ព្រមហើយដោយសទ្ធាដូច្នោះ ក៏មិនប្រាថ្នានឹងទៅកាន់សំណាក់នៃព្រះសាស្តាឡើយ, មិនប្រាថ្នានឹងស្តាប់ធម៌, មិនប្រាថ្នានឹងធ្វើការខ្វល់ខ្វាយដល់សង្ឃ, សូម្បីត្រូវបិតានិយាយថា អ្នកកុំធ្វើយ៉ាងនេះ កូន ក៏មិនស្តាប់ពាក្យរបស់គាត់ ។

លំដាប់នោះ បិតារបស់គេគិតថា កូនកាឡៈនេះ កាលប្រកាន់ទិដ្ឋិបែបនេះ នឹងជាអ្នកមានអវិចីជាទីទៅខាងមុខ, ក៏កាលយើងនៅឃើញបុត្ររបស់យើងទៅកាន់នរក, ទុំះមិនសមគួរដល់យើងឡើយ, ក៏ឈ្មោះថាសត្វអ្នកមិនសំឡឹងរំពៃ ព្រោះ

ការឲ្យទ្រព្យ មិនមានក្នុងលោកនេះឡើយ, យើងនឹងទំលាយ ទិដ្ឋិបុត្រនោះដោយទ្រព្យ ។

លំដាប់នោះ សេដ្ឋីនិយាយនឹងនាយកាឡៈនោះថា កូន ចូរជាអ្នករក្សាឧបោសថ ទៅកាន់វិហារស្តាប់ធម៌ ហើយមកចុះ, យើងនឹងឲ្យកហាបណៈ ១០០ ដល់អ្នក ។

កាឡៈ. នឹងឲ្យឬ ពុក ?

សេដ្ឋី. នឹងឲ្យ កូន ។

កាលកាឡៈនោះទទួលប្តេជ្ញា ៣ ដងហើយ ជាអ្នករក្សាឧបោសថ បានទៅកាន់វិហារ, តែកិច្ចដោយការស្តាប់ធម៌របស់គេមិនមាន, គេដេកក្នុងទីតាមសេចក្តីសប្បាយ បានទៅផ្ទះអំពីព្រលឹម ។ លំដាប់នោះ បិតារបស់គេនិយាយថា បុត្ររបស់យើងបានជាអ្នករក្សាឧបោសថ, អ្នកទាំងឡាយ ចូរនាំយកជាដើមមកឲ្យគេដោយរហ័ស ហើយក៏ប្រើមនុស្សឲ្យឲ្យ ។ នាយកាឡៈនោះហាមអាហារ ដោយនិយាយថា យើងមិនទាន់បានទទួលកហាបណៈ នឹងមិនបរិភោគ ។ លំដាប់នោះ បិតារបស់គេ កាលអត់ធន់ការរំអុកមិនបាន ក៏ឲ្យបង្វេចកហាបណៈ ។

នាយកាឡៈនោះ បន្ទាប់អំពីទទួលកហាបណៈទុកក្នុងដៃហើយ ទើបបរិភោគអាហារ ។

តមក ក្នុងថ្ងៃព្រឹកឡើង សេដ្ឋីប្រើគេទៅដោយនិយាយថា កូន យើងនឹងឲ្យកហាបណៈ ១០០០ ដល់ឯង, ឯងឈរខាងមុខព្រះភក្ត្ររបស់ព្រះសាស្តា រៀនយកបទនៃធម៌ ឲ្យបានមួយបទហើយ សឹមមក ។ នាយកាឡៈទៅវិហារ ហើយឈរចំព្រះភក្ត្រព្រះសាស្តា បានជាអ្នកប្រាថ្នារៀនយកបទនៃធម៌ ១ បទប៉ុណ្ណោះ ហើយចៀសចេញទៅ ។ លំដាប់នោះ ព្រះសាស្តាបានទ្រង់ធ្វើអាការ គឺចាំមិនបានដល់គេ ។ នាយកាឡៈកំណត់បទនោះមិនបាន ទើបឈរស្តាប់ហើយស្តាប់ទៀត ដោយគិតថា យើងនឹងរៀនបទតទៅ ។ ព្រោះថា ជនទាំងឡាយ ស៊ូស្តាប់ ដោយគិតថា យើងនឹងរៀនឲ្យបាន ឈ្មោះថា ស្តាប់ដោយគោរព ។

ក៏ធម្មតា កាលជនទាំងឡាយស្តាប់យ៉ាងនេះ, ធម៌រមែងឲ្យសោតាបត្តិមគ្គជាដើម ។ សូម្បីនាយកាឡៈនោះ ស្តាប់ធម៌ ដោយគិតថា នឹងរៀនឲ្យបាន ។ សូម្បីព្រះសាស្តា ក៏ទ្រង់ធ្វើអាការ គឺការចាំមិនបានដល់គេ ។ នាយកាឡៈកំពុងឈរប្រើង

ស្តាប់ ដោយគិតថា នឹងរៀនតទៅ ទើបតាំងនៅក្នុងសោតាបត្តិផល ។

## បន្ទុះសោតាបត្តិផលហើយមិនទទួលថ្ងៃឈ្នួល

ក្នុងថ្ងៃព្រឹកឡើង នាយកាឡៈនោះ ទៅកាន់ក្រុងសាវត្ថី ព្រមទាំងភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន មហាសេដ្ឋីគ្រាន់តែឃើញកូន ក៏គិតថា ថ្ងៃនេះ យើងពេញចិត្តអាការរបស់បុត្រ ។ ឯនាយកាឡៈនោះ ក៏បានមានបរិវិតក្កយ៉ាងនេះថា ឱហ្ន៎ ! ថ្ងៃនេះ បិតារបស់យើង មិនគប្បីឲ្យកហាបណៈ ក្នុងទីជិតព្រះសាស្តា, គប្បីបិទបាំងសេចក្តីដែលយើងជាអ្នករក្សាឧបោសថ ព្រោះហេតុនៃកហាបណៈ ។ តែព្រះសាស្តាបានទ្រង់ជ្រាបនូវសេចក្តីដែលនាយកាឡៈនោះ ជាអ្នករក្សាឧបោសថ ព្រោះហេតុនៃកហាបណៈហើយ តាំងអំពីថ្ងៃម្សិលមិញ មហាសេដ្ឋីឲ្យគេថ្វាយបបរដល់ព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានហើយ ក៏ប្រើឲ្យឲ្យដល់បុត្រ ។ នាយកាឡៈនោះ ជាអ្នកអង្គុយស្ងៀមដូចសត្វស្វាបសំកាំងស្វាបហើរ ស្រស់ស្រូបបបរ ទំពារបស់គួរទំពា បរិភោគភត្ត ។

ក្នុងវេលាស្រេចភត្តកិច្ចរបស់ព្រះសាស្ដា មហាសេដ្ឋីឲ្យបុគ្គលដាក់បង្វេចកហាបណៈ ១០០០ ទុកខាងមុខ ហើយនិយាយថា កូន បិតានិយាយនឹងឲ្យកហាបណៈ ១០០០ ដល់ឯង ឲ្យឯងសមាទានឧបោសថ ប្រើទៅវិហារ, នេះកហាបណៈ ១០០០ របស់អ្នក ។ នាលកាឡៈនោះ ឃើញកហាបណៈដែលបិតាឲ្យចំពោះព្រះភក្ត្រព្រះសាស្ដា ខ្មាសអៀន ក៏និយាយថា ខ្ញុំមិនត្រូវការដោយកហាបណៈទាំងឡាយ សូម្បីត្រូវបិតានិយាយថា សូមទទួលយកចុះ កូន ក៏មិនទទួលឡើយ ។

## សោតាបត្តិផលប្រសើរជាងសម្បត្តិគ្រប់យ៉ាង

លំដាប់នោះ បិតារបស់គេថ្វាយបង្គំព្រះសាស្ដាហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ថ្ងៃនេះ ខ្ញុំព្រះអង្គពេញចិត្តអាការរបស់បុត្រ កាលព្រះសាស្ដាត្រាស់សួរថា ដូចម្ដេចមហាសេដ្ឋី ? ទើបក្រាបទូលថា ក្នុងថ្ងៃមុន បុត្ររបស់ខ្ញុំព្រះអង្គនេះ គឺខ្ញុំព្រះអង្គនិយាយថា យើងនឹងឲ្យកហាបណៈ ១០០ ដល់អ្នកហើយប្រើទៅវិហារ ក្នុងថ្ងៃព្រឹកឡើង មិនទាន់បានទទួលកហាបណៈ មិនប្រាថ្នានឹងបរិភោគ, តែថ្ងៃនេះ គេមិនប្រាថ្នាកហាបណៈ ដែលខ្ញុំព្រះអង្គឲ្យ ។ ព្រះសាស្ដាត្រាស់ថា ពិតហើយ

មហាសេដ្ឋី, ថ្ងៃនេះ សោតាបត្តិផលនោះឯងនៃបុត្ររបស់អ្នក ប្រសើរជាងសម្បត្តិស្តេចចក្រពត្តិ ប្រសើរជាងសម្បត្តិទេវលោក និងព្រហ្មលោក ហើយត្រាស់ព្រះគាថានេះថា ៖

**១១ បឋព្យា ឯករជ្ជេន សគ្គស្ស គមនេន វា**
**សព្វលោកាធិបច្ចេន សោតាបត្តិផលំ វរំ ។**

សោតាបត្តិផល ជាគុណជាតដ៏ប្រសើរជាងភាព
នៃឯករាជ្យលើផែនដីផង ជាដំណើរទៅកាន់ឋានសួគ៌
ផង ជាងភាពជាធំក្នុងលោកទាំងមូលផង ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បាទព្រះគាថាថា **បឋព្យា ឯករជ្ជេន** គឺជាងភាពជាស្តេចចក្រពត្តិ ។ បាទព្រះគាថាថា **សគ្គស្ស គមនេន វា** សេចក្ដីថា ជាងការដល់សួគ៌ ២៦ ជាន់ ។ បាទព្រះគាថាថា **សព្វលោកាធិបច្ចេន** សេចក្ដីថា ជាងភាពជាធំក្នុងលោក មានប្រមាណប៉ុណ្ណោះៗ គឺក្នុងលោកទាំងពួង ព្រមទាំងនាគ គ្រុឌ និងវេមានិកប្រេត ។ បាទព្រះគាថាថា **សោតាបត្តិផលំ វរំ** សេចក្ដីថា ព្រោះព្រះរាជា សូម្បីសោយរាជសម្បត្តិក្នុងទីមានប្រមាណប៉ុណ្ណោះ ក៏ជាអ្នកមិនផុតចាកនរកជាដើម

បានឡើយ ចំណែកព្រះសោតាបន្ន ជាអ្នកមានទ្វារអបាយបិទហើយ សូម្បីមានកំឡាំងខ្សោយជាងព្រះសោតាបន្នទាំងអស់ ក៏មិនកើតក្នុងភពទី ៨ ដូច្នោះ សោតាបត្តិផលនោះឯង ទើបប្រសើរ គឺខ្ពង់ខ្ពស់ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនទាក់សំរេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ៕

រឿងនាយកាឡបុត្រអនាថបិណ្ឌិកសេដ្ឋី ចប់

លោកវគ្គវណ្ណនា ចប់

វគ្គទី ១៣ ចប់

*********